**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# មោឃភាពនៃនីតិវិធីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ច័ន្ទតារា រ៉ូម៉ែន**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

សរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# មោឃភាពនៃនីតិវិធីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ច័ន្ទតារា រ៉ូម៉ែន**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
សរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ច័ន្ទតារា រ៉ូម៉ែន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី ១៩នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំ ២០១៨ និង ២០១៩

ជាដំបូងខ្ញុំបាន សូមថ្លែងអំណរគុណលំអោនកាយចិត្ត និងសម្ដែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុកឈ្មោះ ឡឹក ច័ន្ទតារា** **អ្នកម្ដាយឈ្មោះ ប៉ុក ពិរក្សរដ្ឋ**

ដែលលោកអ្នកមានគុណទាំងពីរបានផ្ដល់កំណើតព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាគ្រប់គ្រង់ និងអប់រំកូនទាំងពីតូចរហូតដល់ធំពេញវ័យ និងអាចជានិស្សិតល្អ ពលរដ្ឋល្អនៅក្នុងសង្គម។ ប្រសិនបើពុំមានការគាំទ្រយ៉ាងពេញទំហឹងខាងផ្នែកសម្ភារៈនិងផ្នែកស្មារតីពីសំណាក់រូបលោកទាំងពីរទេ ដូចនេះកូនក៏មិនអាចដើរដល់ថ្ងៃដែរ។ លើសពីនេះទៀតអាស្រ័យដោយមានការគាំទ្ររបស់លោកទើបធ្វើអោយកូនតែងតែទទួលបាននូវភាពជោគជ័យនៅក្នុងគ្រប់ភារកិច្ចជាពិសេសការសិក្សារហូតអាចសម្រេចកិច្ចការសារណានេះ ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រងសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យ ការិយាល័យស្រាវជ្រាវ និងបុគ្គលិកសិក្សានៅក្នុង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានជួយសម្រួលដល់កិច្ចការរបស់ខ្ញុំបាទ ។

ជាពិសេសខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលបានចំណាយពេលវេលាដល់មានតម្លៃ ព្រមទាំងកម្លាំងកាយកម្លាំងចិត្ត និងការណែនាំពិនិត្យកែសម្រួល និងកែប្រែកំហុសឆ្គងកិច្ចការសាលានេះថែមទាំងចង្អុលបង្ហាញនូវប្រភពឯកសារ និងព័ត៌មាននានាដែលទាក់ទងទៅ នឹងប្រធានបទសារណាដល់ខ្ញុំអាចចងក្រងបានស្នាដៃសារណាមួយនេះឡើង ។

ជាចុងបញ្ចប់ រូបខ្ញុំបាទមិនអាចបំភ្លេចនូវគុណដ៏មានតម្លៃទាំងនេះហើយ សូមធ្វើការគោរពឱនកាយវាចាចិត្តសម្ដែងនូវការដឹងគុណ និងសូមប្រសិទ្ធពរជ័យបួងសួងដល់ គុណព្រះរតនត្រៃ និងវត្ថុសាកសិទ្ធក្នុងលោកតាមជួយថែរក្សា **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រងសាកលវិទ្យាល័យ លោក លោកស្រី សាស្ត្រាចារ្យ ការិយាល័យស្រាវជ្រាវ និងបុគ្គលិក**ទាំងអស់គ្នានិងសូមឲ្យជួបតែនឹងពុទ្ធពរទាំង ៤ ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# **អារម្ភកថា**

បន្ទាប់ពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងរយៈពេល ៤ឆ្នាំ នៅ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** យើងខ្ញុំក៏សម្រេចចិត្តជ្រើសរើសយក ប្រធានបទស្តី " **មោឃភាព** "ដែលមានលោកសាស្ត្រាចារ្យដឹងនាំលោក **ជួន ប៊ុនធី** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

នៅពេលបច្ចុប្បន្ន ប្រព័ន្ធតុលាការកំពុងតែមានការរីកចម្រើនឡើងខ្លាំង បើគិតនៅប៉ុន្មានទសវត្សចុងក្រោយនេះ បានន័យថា កាលពីសម័យមុខ ប្រទេសកម្ពុជាមិនសូវមានច្បាប់សម្បូរបែប បូករួមទាំងសម័យកាលដល់ឈឺចាប់បំផុតគឺ សម័យខ្មែរក្រហម ឬ ហៅយ៉ាងទៀតថា របបកម្ពុជាប្រជាធិបតេយ្យ ( ១៩៧៥ ដល់ ១៩៧៩ )។ គ្រប់យ៉ាងនៅកម្ពុជាសុទ្ធសឹងតែខ្ទិចទាំងស្រុង ទាំងហេដ្ឋារចនាសម្ព័ន និងទម្រង់គ្រប់គ្រងរដ្ឋ។ សព្វថ្ងៃកម្ពុជា កំពុងស្វះស្វែងរកនៅវិធានច្បាប់ និងការបង្កើតច្បាប់ដើម្បីគ្រប់គ្រងអោយទាន់ទៅនឹងស្ថានភាពសង្គមនាពេល បច្ចុប្បន្ន ក៏ដូចជា ការទទួលយកនូវច្បាប់អន្តរជាតិ តាមរូបភាព កតិកាសញ្ញា សន្ធិសញ្ញា ជាអាទ៍ និងការបង្កើតច្បាប់ដោយខ្លួនឯងតាមស្ថានភាពសង្គមជាក់ស្តែង ។

នៅពេលបច្ចុប្បន្ន ទោះបីជាប្រព័ន្ធតុលាការមានការរីកចម្រើនក៏ដោយ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅចំណុចខ្លះ កំពុងតែជាបញ្ហាដល់ក្តៅមួយនៅក្នុងសង្គមបច្ចុប្បន្ន។ ទើបថ្ងៃនេះខ្ញុំបានធ្វើការលើកយកបញ្ហាមួយមកបកស្រាយគឺ មោឃៈភាពក្នុងនីតិវិធីព្រហ្មទណ្ឌ ។ ប្រធានបទនេះកំពុងតែជាបញ្ហាធំមួយដែលអ្នកអនុវត្តច្បាប់នៅកម្ពុជាមើលរំលង។ គ្រប់ដំណាល់ក្នុងរឿងក្តីព្រហ្មទណ្ឌ ប្រសិនបើមានការអនុវត្តខុសនៅបទប្បញ្ញត្តិណាមួយនោះ វាអាចជាឱកាសដល់ជនខិលខូចរួចផុតពីសំណាញ់ច្បាប់ ហើយក៏ជាចំណុចល្អមួយដែលមេធាវីគ្រប់រូបធ្វើជាមូលដ្ឋានក្នុងការការពារកូនក្តីរបស់ខ្លួន ។

សង្ឃឹមថាសារណាមួយនេះនឹងក្លាយទៅជាចំណែកនៃចំណេះដឹង នីតិសាស្ត្រក្នុងការដោះស្រាយរឿងនីតិវិធីព្រហ្មទណ្ឌ ហើយក៏រំពឹងថាវានិងអាចក្លាយទៅជាដើមទុនមួយសម្រាប់និស្សិត និងមិត្តភក្តិអ្នកអានក្នុងការសិក្សាស្រាវជ្រាវផ្នែកមួយនេះ ទោះជាយ៉ាងណាក៏ដោយខ្ញុំជឿថាស្នាដៃនេះនៅតែមានចំណុចខ្វះខាតហើយខ្ញុំសូមស្វាគមន៍ជានិច្ចចំពោះការរិះគន់ក្នុងន័យស្ថាបនា ។

# មាតិកា

លេខទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## មូលហេតុនៃមោឃភាព

**កថាខណ្ឌទី១ មោឃៈភាពក្នុងដំណាក់កាលស៊ើបអង្កេត** ........ ៣

**១.១. កិច្ចនីតិវិធីក្នុងការស៊ើបអង្កេតជាក់ស្តែង** ........ ៤

១.១.១. កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ ........ ៤

១.១.២ ការឆែកឆេរ ........ ៤

១.១.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង ........ ៧

១.១.៤ កំណត់ហេតុលើការស្តាប់ចម្លើយ ........ ៧

១.១.៥ បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង ........ ៧

១.១.៦ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ ........ ៨

១.១.៧ ការឃាត់ខ្លួន ........ ៨

១.១.៨ កំណត់ហេតុស្តីពីការឃាត់ខ្លួន ........ ១០

១.១.៩ ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន ........ ១១

១.១.១០ ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន ........ ១២

១.១.១១ អនីតិជនដែលត្រូវបានឃាត់ខ្លួន ........ ១២

១.១.១២ ការហាមឃាត់មិនឲ្យស្តាប់ដោយឯង ជាអាទ៍ ........ ១៣

១.១.១៣ ថិរពេលានៃការស៊ើបអង្កេតករណីជាក់ស្តែង ........ ១៣

១.១.១៤ និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ ........ ១៤

**១.២ កិច្ចនីតិវិធីក្នុងការស៊ើបអង្កេតបឋម** ........ ១៤

១.២.១ ការឃាត់ខ្លួន ........ ១៥

១.២.២ កំណត់ហេតុស្តីពីការឃាត់ខ្លួន ........ ១៧

១.២.៣ អនីតិជនដែលត្រូវបានឃាត់ខ្លួន.......................................................................១៨
១.២.៤ ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទ៍ ..................................................១៨
១.២.៥ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា.....................................................................១៨
១.២.៦ ការឆែកឆេរ .....................................................................................................................១៩
១.២.៧ ការបញ្ជាឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម.................................................................២០
**កថាខណ្ឌ២ មោឃៈភាពក្នុងដំណាក់កាលស៊ើបសួរ**............................................................ ២០
**១.១ កិច្ចនីតិវិធីក្នុងដំណាក់កាលស៊ើបសួរ**................................................................................២១
**១.២ កិច្ចនីតិវិធីដែលអាចមោឃភាពបាន** .................................................................................២២
១.២.១ ការបើកស៊ើបសួរ............................................................................................................ ២២
១.២.២ សមត្ថកិច្ចដែនដី ........................................................................................................... ២២
១.២.៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ.............................................................................២៣
១.២.៤ វិសាលភាពនៃការប្តឹង.......................................................................................................២៤
១.២.៥ ជំនួយរបស់ក្រឡាបញ្ជី ......................................................................................................២៤

## ជំពូកទី២
## នីតិវិធីនៃការមោឃៈភាព

**កថាខណ្ឌទី១ ស្ថាប័នមានសមត្ថកិច្ច និងរយៈពេលនៃការប្តឹង**...................................................២៦
**២.១ ស្ថាប័នដែលមានសមត្ថកិច្ច**..................................................................................................២៧
២.១.១ រយៈពេលនៃការប្តឹង......................................................................................................... ៣០
២.១.២ ចំណាត់ការលើបណ្តឹងមោឃៈភាព.................................................................................. ៣០
**២.២ ការដាក់ពាក្យបណ្តឹង** .............................................................................................................៣០
២.២.១ ការពិនិត្យ និងទទួលបណ្តឹង ...............................................................................................៣១
២.២.២ ការពិភាក្សាដេញដោល និងការសម្រេចសេចក្តី.....................................................................៣១
ក/ ដំណាក់កាលពិភាក្សាដេញដោល................................................................... ៣១
ខ/ ដំណាក់កាលសម្រេចសេចក្តី......................................................................... ៣២

# ជំពូកទី៣
# អានុភាពនៃការមោឃភាពនីតិវិធី

**កថាខណ្ឌទី១ ដំណាក់កាលស៊ើបអង្កេត** ..................... ៣៣

**៣.១ ការបញ្ឈប់សុពលភាពនៃកិច្ចស៊ើបអង្កេត** ..................... ៣៣

៣.១.១ អនុវត្តកិច្ចនៃនីតិវិធីសាជាថ្មី..................... ៣៤

៣.១.២ ដំណាក់កាលស៊ើបសួរ..................... ៣៥

**៣.២ បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ** ..................... ៣៥

៣.២.១ ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ..................... ៣៥

៣.២.២ បន្តការស៊ើបសួរដោយខ្លួនឯង ..................... ៣៦

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. បុព្វហេតុ

ច្បាប់ត្រូវបានបង្កើតឡើងដើម្បីធ្វើការគ្រប់គ្រងសណ្តាប់ធ្នាប់ និងស្ថិរភាពសង្គមមួយ ដើម្បីប្រកបទៅដោយភាពសុខសាន្ត និងការអភិវឌ្ឍន៍នៃប្រទេសមួយ។ ប៉ុន្តែនៅលើសកលលោកច្បាប់ត្រូវបានបែងចែងជាពីរធំៗ គឺ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ទន្ទឹមនឹងនេះ ឈ្លាតពេលនេះខ្ញុំបាទសូមធ្វើការលើកយកផ្នែកមួយដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ធ្វើការយកមកបកស្រាយ និងពិភាក្សាដេញដោលដើម្បីបង្កើតនៅគំនិតថ្មី និងចំណេះដឹងថ្មី។ **មោឃៈភាព** គឺជាទណ្ឌកម្មចំពោះការមិនគោរពលក្ខខណ្ឌសុពលភាពនៃកិច្ចគតិយុត្ត។ កិច្ចដែលត្រូវបានលុបចោល ត្រូវចាត់ទុកថា មិនដែលកើតមានឡើងនោះទេ។ មោឃៈភាពត្រូវប្រកាសឡើងដោយឈរលើច្បាប់ដែលចូលជាធរមាន ឬ នីតិវិជ្ជមាន។ ច្បាប់នីតិវិធីថ្មីមិនមានអនុភាពទៅលើសុពលភាព នៃកិច្ចនីតិវិធីដែលធ្វើឡើងក្រោមច្បាប់ចាស់នោះទេ។ ច្បាប់ថ្មីត្រូវអនុវត្តភ្លាម និង មិនប្រតិសកម្ម។ ដំណាក់កាលចំនួន ៤ នៃមោឃកម្ម៖ មូលហេតុនៃមោឃៈភាព មោឃៈភាពដែលប្រកាស ការអនុវត្តនៃមោឃៈភាព និង ការអនុភាពនៃមោឃៈភាព។

## ២. ចំណោទបញ្ហា

ទន្ទឹមនឹងការលើកឡើងខាងលើមានបញ្ហា និងចម្ងល់មួយចំនួនត្រូវបានលើកឡើងពាក់ព័ន្ធនឹងមោឃៈភាពថា *តើមោឃភាពត្រូវបានយកមកប្រើ នៅក្នុងស្ថានភាពណា? ដើម្បីអ្វី? ហើយត្រូវគោរពតាមលក្ខខណ្ឌ និងមូលហេតុអ្វីខ្លះ? ហើយមានលំហូរនីតិវិធីយ៉ាងដូចម្តេច?*

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវប្រធានបទ **មោឃៈភាព** នេះកំពុងតែជាបញ្ហាធំមួយដែលអ្នកអនុវត្តច្បាប់នៅកម្ពុជា មើលរំលង។ គ្រប់ដំណាល់ក្នុងរឿងក្តីព្រហ្មទណ្ឌ ប្រសិនបើមានការអនុវត្តខុសនៅបទប្បញ្ញត្តិណាមួយនោះ វាអាចជាឱកាសដល់ជនខិលខូចរួចផុតពីសំណាញ់ច្បាប់ ហើយក៏ជាចំនុចល្អមួយដែលដែរមេធាវីគ្រប់រូប ធ្វើជាមូលដ្ឋានក្នុងការការពារកូនក្តីរបស់ខ្លួន ។

សង្ឃឹមថាសារណាមួយនេះនឹងក្លាយទៅជាចំណែកនៃចំណេះដឹង ឬ នីតិសាស្ត្រក្នុងការដោះស្រាយរឿងនីតិវិធីព្រហ្មទណ្ឌ ហើយក៏រំពឹងថាវានិងអាចក្លាយទៅជាដើមទុនមួយសម្រាប់និស្សិត និងមិត្តភក្តិអ្នកអានក្នុងការសិក្សាស្រាវជ្រាវផ្នែកមួយនេះ។

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

ទាក់ទងទៅនឹងការស្រាវជ្រាវបញ្ចប់ការសិក្សាផ្នែកបរិញ្ញាប័ត្រនីតិសាស្ត្រនេះយើងខ្ញុំបានយកចិត្តទុកដាក់ដល់សំខាន់តែនៅលើចំនុចនានា ដែលពាក់ព័ន្ធទៅនឹងមោឃៈភាព តាំងពីដំណាក់កាលរបស់មន្ត្រីនគរបាល

យុត្តិធម៌ដំណាក់កាលរបស់អយ្យការ ដំណាក់កាលរបស់ចៅក្រមស៊ើបសួរ និងការសម្រេចរបស់សភាស៊ើបសួរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវគោលបំណង នៃការស្រាវជ្រាវខាងលើយើងបានធ្វើការសិក្សា និងឯកសារដែលមានលក្ខណៈជាទ្រឹស្តីជាច្រើនពាក់ព័ន្ធ នឹងប្រធានបទ ហើយបានយកមកគួបផ្សំជាមួយនឹងការអនុវត្តជាក់ស្តែងតាមរយៈការចុះបំពេញការងារជាមួយមេធាវីនៅសាលាដំបូងរាជធានី-ខេត្ត។ ទន្ទឹមនឹងនេះ ចំពោះប្រភពឯកសារដែលជាទ្រឹស្តីមានជាប្រភេទគឺ លិខិតបទដ្ឋានគតិយុត្តជាតិ លិខិតបទដ្ឋានអន្តរជាតិ សៀវភៅ គេហទំព័រ ព្រមទាំងឯកសារគតិយុត្តផ្សេងៗទៀត។ ក្នុងនោះដែរក៏មានការចូលរួមចែករំលែកផ្តល់នូវដំបូន្មានល្អៗរបស់ លោកគ្រូសាស្ត្រាចារ្យដឹកនាំសារណាបញ្ចប់ការសិក្សា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី និងជំនួយការដែលធ្លាប់មានបទពិសោធន៍អនុវត្តពាក់ព័ន្ធនឹងប្រធានបទខាងលើនេះផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដូចនេះជាដំណោះស្រាយ ក៏ដូចជាការឆ្លើយតបដើម្បីយល់ច្បាស់ទាក់ទងទៅនឹងបញ្ហាគតិយុត្តដែលមានជាចំណោទបញ្ហាខាងលើនេះ ការសិក្សាអំពីប្រធានបទទាក់ទងទៅនឹងមោឃភាពនីតិវិធី យើងសូមធ្វើការបកស្រាយចែកចេញជាបីជំពូកធំៗ៖ មូលហេតុនៃមោឃភាព នីតិវិធីនៃមោឃភាព និងអនុភាពនៃមោឃភាពនីតិវិធី។

# ជំពូកទី១

# មូលហេតុនៃអោយៈភាព

# ជំពូកទី១

# មូលហេតុនៃមោឃភាព

មូលហេតុមោឃៈភាព គឺជាកត្តាមួយដែលធ្វើឲ្យ ចលនាប្តឹងមានភាពរាំងស្ទះបូករួមផ្សំទាំងកិច្ចនីតិវិធី។ ទន្ទឹមនឹងនេះ មោឃភាពក៏ជាកត្តាមួយដែលនាំប្រយោជន៍ដល់ជនល្មើសផងដែរ។ នៅក្នុងស្ថានភាពជាក់ស្តែង មូលហេតុមោឃៈភាព គឺជាចំណុចពិសេសមួយ ដែលភាគីនៃរឿងក្តីតែងតែលើកយកមកធ្វើជាសំអាង ដើម្បីធ្វើជាផលប្រយោជន៍ក្នុងការពារខ្លួនក៏ដូចជា ការលើកឡើងទាក់ទងទៅ និងការបំពានសិទ្ធិរបស់ពួកគេជាដើម។ មោឃៈភាពតែងតែកើតចេញមកពី ២ដំណាក់កាលៈ ដំណាក់កាលនៃការស៊ើបអង្កេត និង ដំណាក់កាលនៃការស៊ើបសួរ។ ដើម្បីកាន់តែយល់ដឹងច្បាស់ ការបង្ហាញ និង បកស្រាយចម្ងល់មាននៅក្នុង កថាកណ្ឌទី១ មោឃៈភាពក្នុងដំណាក់កាលស៊ើបអង្កេត និង កថាខណ្ឌទី២ មោឃៈភាពក្នុងដំណាក់កាលស៊ើបសួរ។

## កថាខណ្ឌទី១ មោឃៈភាពក្នុងដំណាក់កាលស៊ើបអង្កេត

ការស៊ើបអង្កេតបឋម និង ការស៊ើបអង្កេតជាក់ស្តែង គឺធ្វើឡើងក្នុងគោលបំណង ដើម្បីធ្វើការប្រមូលរកភស្តុតាង ក្នុងការកំណត់បទល្មើស។ ជាការពិតណាស់ ការស៊ើបអង្កេតត្រូវធ្វើឡើងក្រោមរូបភាពដោយនគរបាលយុត្តិធម៌។ រួមជាមួយគ្នានេះបេសកកម្មរបស់នគរបាលយុត្តិធម៌គឺជា ជំនួយការរបស់អំណាចតុលាការទៅតាមច្បាប់កំណត់។ យ៉ាងណាមិញពាក្យថា ជំនួយនេះគឺជាការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅដើម្បីឈានទៅរកការកំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាងជាដើម។ សមាសភាពមន្រ្តីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតមានដូចជា មន្រ្តីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្រ្តីសាធារណៈដទៃទៀតដែលច្បាប់ផ្តល់សិទ្ធិអំណាចឲ្យ។ ក្នុងនោះផងដែរ ការស៊ើបអង្កេតត្រូវដឹកនាំ និងសម្របសម្រួលដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ និងមានការត្រួតពិនិត្យដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ឈានមកដល់ចំណុចនេះ មោឃៈភាពក្នុងដំណាក់កាលស៊ើបអង្កេតសំដៅទៅលើការប្រព្រឹត្តកំហុសឆ្គងស៊ើបអង្កេតរបស់មន្រ្តីអនុវត្តធ្វើផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ ដែលមានចែងចូលជាធរមាន។ ដើម្បីកំណត់បទល្មើសមួយទៅបាន លុះត្រាតែមន្រ្តីនគរបាលយុត្តិធម៌ធ្វើការបើកស៊ើបអង្កេត និងកំណត់បទល្មើសក្នុងការងាយស្រួលដើម្បីបញ្ជូនសំណុំរឿងតាមនីតិវិធីបន្ត។ ទន្ទឹមនឹង នេះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានធ្វើការបែងចែកកិច្ចស៊ើបអង្កេតចែកចេញជា២ៈ ការស៊ើបអង្កេតជាក់ស្តែង[1] និង ការស៊ើបអង្កេតបឋម[2]។

---

[1] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ៨៥ ដល់ ១១១

[2] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១១១ ដល់ មាត្រា១១៨

## ១.១. កិច្ចនីតិវិធីក្នុងការស៊ើបអង្កេតជាក់ស្តែង

កិច្ចនីតិវិធីក្នុងការស៊ើបអង្កេតជាក់ស្តែង គឺជាចំណាត់ការដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតទៅលើបទល្មើសជាក់ស្តែងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌បានធ្វើការបើកការស៊ើបអង្កេតបទល្មើស ក្នុងករណីបទល្មើសជាក់ស្តែង ចំណាត់ការឈានទៅរកការស៊ើបអង្កេតមាននេះដូចជា ៖

### ១.១.១. កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ គឺជាកត្តាមួយដល់សំខាន់ក្នុងការធ្វើកំណត់យកជាភស្តុតាងឯកសារដាក់ជូនព្រះរាជអាជ្ញា និងតុលាការ។ នៅក្នុងចំណុចនេះជាកាតព្វកិច្ចដាច់ខាត់របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបំពេញកិច្ចនេះ ព្រោះការមិនបានធ្វើកំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យជាកត្តាមួយដែលបង្កជា មូលហេតុដែលភាគីបណ្តឹងអាចស្នើសុំមោឃៈភាព លើកិច្ចនីតិវិធីនេះ[3]។

ឧទាហរណ៍៖ នៅពេលដែលបញ្ជូនជនល្មើសទៅកាន់ព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់។ នៅពេលនោះមេធាវីរបស់ជនល្មើស និងលើកយកបញ្ហាកំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យដោយអះអាងថា មានភាពមិនប្រក្រតី និងបំពានច្បាប់ដែលចូលជាធរមាន ។ បញ្ហានេះអាចជាកត្តាមួយនាំអោយបាត់ភស្តុតាង ឬ អាចនាំអោយមានការដោះលែងទៀតផង ។

### ១.១.២ ការឆែកឆេរ

សិទ្ធិក្នុងការរស់រានមានជីវិតមនុស្សគ្រប់រូបសុទ្ធតែមាន សេចក្តីថ្លៃថ្នូររៀងៗខ្លួនក្នុងនាមជាមនុស្សជាតិ ត្រូវបានការពារដោយច្បាប់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ[4] ដែលកម្ពុជា ទទួលស្គាល់ជាច្បាប់ជាតិ[5]។ ដើម្បីការពារសេចក្តីថ្លៃថ្នូរនេះ ប្រទេសដែលជាហត្ថលេខីត្រូវគោរព ទទួលស្គាល់ ប្រកាន់យកខ្ជាប់នូវការគោរពច្បាប់ និងសិទ្ធិមនុស្ស តែងបង្កើតនូវនីតិវិធីសម្រាប់ឲ្យអាជ្ញាធររដ្ឋ មន្ត្រីរាជការ ក៏ដូចជាមន្ត្រីនគរបាលយុត្តិធម៌ ជាដើម ដើម្បីអនុវត្តនៅពេលចុះឆែកឆេរទីកន្លែង ឬលំនៅឋានណាមួយក្នុងបំណងបំពេញបេសកកម្ម ជៀសវាងការរំលោភអំណាចរបស់សមត្ថកិច្ចរដ្ឋ ទៅលើសិទ្ធិពលរដ្ឋរបស់ខ្លួន។ នៅកម្ពុជា ការចុះឆែកឆេរទីកន្លែងណាមួយ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ការសម្រុកចូលក្នុងទីកន្លែង ឬលំនៅឋានរបស់បុគ្គលណាម្នាក់ គឺជាអំពើជ្រៀតជ្រែកប៉ះពាល់ដល់ជីវភាពរស់នៅឯកជនរបស់អ្នកដទៃដែលច្បាប់ហាមឃាត់ ក៏ប៉ុន្តែសិទ្ធិស្របច្បាប់នេះ អាចត្រូវបានរដ្ឋដកហូតមួយរយៈ ប្រសិនបើបុគ្គលរូបនោះត្រូវគេសង្ស័យថា បានប្រព្រឹត្តបទល្មើសណាមួយ។

---

[3] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩០ និងមាត្រា១០៩

[4] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១៩៦៦)(ចូលជាធរមានជាសកលឆ្នាំ១៩៧៦ និងនៅកម្ពុជាឆ្នាំ១៩៩២)

[5] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

ទោះជាយ៉ាងណា ក្រមនីតិវិធីព្រហ្មទណ្ឌក៏ត្រូវបានបង្កើតឡើង ដើម្បីទប់ស្កាត់ រារាំង អាជ្ញាធរមានសមត្ថកិច្ច មិនឲ្យអនុវត្តច្បាប់ហួសព្រំដែនកំណត់ផងដែរ។

ការអនុវត្តតាមអំពើចិត្តដោយប្រើប្រាស់អំណាចមិនសមស្រប ដែលជាកត្តានាំឲ្យមានការរំលោភសិទ្ធិរស់នៅដ៏សុខសាន្តរបស់ពលរដ្ឋផងដែរ។ វត្ថុតាងទាំងឡាយដែលប្រមូលបានមកពីការឆែកឆេរខុសនីតិវិធីច្បាប់ មិនអាចយកមកប្រើជាភស្តុតាងក្នុងតុលាការបានឡើយ[6]។ ដូចនេះមូលហេតុនាំអោយមានការមោឃៈភាពនៃការឆែងឆេរមាន៤ចំណុចៈ

- ការឆែកឆេរដោយមិនបានរាយការណ៍ទៅថ្នាក់លើ

ដើម្បីបញ្ចៀសការទម្លាក់កំហុសទៅលើជនស្លូតត្រង់ណាម្នាក់ ក្នុងអំឡុងពេលចុះឆែកឆេររកវត្ថុតាងអ្វីមួយនៅក្នុងទីកន្លែង ឬលំនៅឋានណាមួយ នីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា បានកំណត់អំពីវិធី និងតម្រូវការដែលត្រូវអនុវត្តក្នុងពេលចុះឆែកឆេរ។ តាមច្បាប់ជាធរមាន ការចុះឆែកឆេរទីកន្លែង ឬលំនៅឋានរបស់ជនណាម្នាក់ សមត្ថកិច្ចត្រូវមានដីកាឆែកឆេរ ឬ មានការរាយការណ៍ទៅព្រះរាជអាជ្ញា និងត្រូវតែធ្វើឡើងនៅចំពោះមុខម្ចាស់ផ្ទះ ឬម្ចាស់ទីកន្លែងនោះ។ ការឆែកឆេរណាមួយដែលមិនចាំបាច់មានដីកា អាចធ្វើទៅបានសម្រាប់តែបទល្មើសជាក់ស្តែង[7]ប៉ុណ្ណោះ។ ហេតុផលដែលច្បាប់តម្រូវឲ្យធ្វើដូច្នេះ គឺដើម្បីជៀសវាងការទម្លាក់កំហុស ឬការចោទប្រកាន់ណាមួយរវាងម្ចាស់ផ្ទះ និងសមត្ថកិច្ចដែលចុះឆែកឆេរ។

- ការឆែកឆេរដោយមិនមានសាក្សី ឬ សមាសភាពសាក្សីអំឡុងពេលឆែកឆេរ

ហេតុផលចម្បងដែលទាមទារឲ្យម្ចាស់ផ្ទះមានវត្តមាន នៅពេលឆែកឆេរនោះ គឺដើម្បីធានាថា សមត្ថកិច្ចធ្វើត្រឹមត្រូវនៅពេលឆែកឆេរ។ ប៉ុន្តែប្រសិនបើម្ចាស់ផ្ទះ ឬម្ចាស់ទីកន្លែងមិនមានវត្តមាននៅពេលឆែកឆេរនោះទេ ការឆែកឆេរក៏អាចធ្វើទៅបានដែរ ប៉ុន្តែលុះត្រាតែមាន ព្រះរាជអាជ្ញា និងវត្តមានរបស់សាក្សីមានសារសំខាន់ណាស់ក្នុងពេលឆែកឆេរ នៅពេលណាមិនមានវត្តមានម្ចាស់ផ្ទះ។

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ស្តីពីការឆែកឆេរ និងការចាប់យកវត្ថុតាង[8] ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី២ (ពីរ) នាក់ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

យោងតាមបទប្បញ្ញត្តិច្បាប់កំណត់ មន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តើមការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ)

[6] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩១ និងមាត្រា១០៩

[7] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៨៦និងមាត្រា១០៩

[8] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩២និងមាត្រា១០៩

ព្រឹក និងក្រោយម៉ោង ៦ (ប្រាំមួយ) ល្ងាចបានទេ៖ លើកលែងតែ ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរនៅពេលងងឹត ឬមិនមានពន្លឺគ្រប់គ្រាន់ អាចមានគ្រោះថ្នាក់ដល់គ្រប់ភាគី និងមានការងាយស្រួលដល់ការក្លែងបន្លំទម្លាក់កំហុសដល់ម្ចាស់ទីកន្លែង ឬ ម្ចាស់ផ្ទះ។

គោលបំណងនៃការឆែកឆេរនៅទីកន្លែងណាមួយ គឺដើម្បីស្វែងរកវត្ថុតាងដែលជាប់សង្ស័យក្នុងបទល្មើសណាមួយ។ ទោះជាយ៉ាងណាវត្ថុតាងទាំងឡាយណាដែលបានមកពីការឆែកឆេរគ្មានដីកា គ្មានវត្តមានម្ចាស់ទីកន្លែង ឬគ្មានសាក្សីពីរនាក់ គឺការជាការឆែកឆេរមិនស្របច្បាប់។ វត្ថុតាងទាំងឡាយដែលប្រមូលបានមកពីការឆែកឆេរខុសនីតិវិធីច្បាប់ មិនអាចយកមកប្រើជាភស្តុតាងក្នុងតុលាការបានឡើយ។ ដូចនេះមូលហេតុនាំឲ្យមានការមោឃៈភាពនៃការឆែងឆេរមាន៤ចំណុច៖

- ការឆែកឆេរដោយមិនគោរពអំឡុងពេល

ការឆែកឆេរមិនមានការគោរពតាមពេលវេលាដែលច្បាប់បានកំណត់ ពោលគឺមិនអាចធ្វើការឆែកឆេរមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង៦ល្ងាចឡើយ ប្រសិនបើមានការឆែកឆេរខុសពេលបែបនេះអាចជាមូលហេតុស្នើសុំមោឃៈភាពកិច្ចនីតិវិធី ។ លើកលែងតែមានករណីចាំបាច់មួយចំនួន៖

1. ករណីបទល្មើសជាក់ស្តែង
2. ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង
3. ករណីមានសំរែកស្រែកឲ្យគេជួយពីក្នុងទីកន្លែ
4. ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សារធារណជន
5. ករណីឆែកឆេរទាក់ទងនិងគ្រឿងញៀន

- ការឆែកឆេរដោយមិនគោរពតាមទម្រង់ច្បាប់កំណត់ ( ការិយាល័យមេធាវី និង អគារ សហគ្រាសសារព័ត៌មាន

ការឆែកឆេរដោយមិនគោរពតាមទម្រង់ច្បាប់កំណត់ គឺជាការឆែកឆេរដោយគ្មានបែបបទត្រឹមត្រូវដូចជា៖

1. ការឆែកឆេរការិយាល័យមេធាវីដោយគ្មានព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ
2. ការឆែកឆេរការិយាល័យមេធាវីដោយមិនធ្វើឡើងចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូប្រធានគណៈមេធាវី ឬ មេធាវីសាមី។

១ ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩១និងមាត្រា១០៩

### ១.១.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង

ការបិតស្លាកបោះត្រាលើវត្ថុតាង គឺជាការបិទដើម្បីធានាអោយបាននៅភស្តុតាងដោយត្រឹមត្រូវពិតប្រាកដ និងគ្មានការផ្លាស់ប្តូរក្រោយពេលដែលមន្ត្រីនគរបាលរកឃើញទៅភស្តុតាងនោះ។ ការយកភស្តុតាងមកដោយគ្មានការបិទស្លាកបោះត្រាលើវត្ថុតាងអាចជាបញ្ហាមួយដែលអាចនិងមានការស្នើសុំមោឃៈភាពកិច្ចនីតិវិធីនេះបាន ពោលគឺអាចជាភស្តុតាងមិនស្របច្បាប់ ឬ ភស្តុតាងក្លែងក្លាយ[10]។

ឧទាហរណ៍៖ ការរកឃើញកាំបិត ដែលជាភស្តុតាងក្នុងការប្រព្រឹត្តបទល្មើស។

### ១.១.៤ កំណត់ហេតុលើការស្តាប់ចម្លើយ

ជាគោលការណ៍មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអាចធ្វើការហៅ និងនាំខ្លួនបុគ្គលគ្រប់រូបដែលខ្លួនយល់ឃើញថា មានការសង្ស័យចូលរួមប្រព្រឹត្តក្នុងបទល្មើស។ ការស្តាប់ចម្លើយនីមួយៗ ត្រូវធ្វើកំណត់ហេតុហើយកំណត់ហេតុនោះត្រូវមានចុះហត្ថលេខា ឬ ផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ។ ក្នុងការចុះហត្ថលេខា ឬ ផ្តិតម្រាមដៃបុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ក្នុងករណីមិនចេះអាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអានឲ្យ ឬ បកប្រែ។ ប៉ុន្តែការធ្វើកំណត់ហេតុស្តាប់ចម្លើយខាងលើមិនអាចធ្វើឡើងដោយប្រើហឹង្សា ឬ ដោយការបង្ខំ ឬ គំរាមដោយរូបភាពណាមួយបានទេ។ ប្រសិនបើមានការធ្វើដូចទៅនឹងស្ថានភាពខាងលើ វាអាចជាមូលហេតុមួយដែលអាចនាំឲ្យមានការប្តឹងសុំមោឃៈភាពកិច្ចនីតិវិធីនេះ[11]។

ឧទាហរណ៍៖ ការទទួលបានចម្លើយដោយការ ប្រើប្រាស់ការបង្ខំគ្រប់រូបភាព។

### ១.១.៥ បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺជាការកោះហៅបុគ្គលគ្រប់រូបដែលមន្ត្រីនគរបាលយុត្តិធម៌យល់ឃើញថា អាចមានពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតបទល្មើស។ យ៉ាងណាមិញបទបញ្ជាឲ្យចូលខ្លួនត្រូវមានការគោរពទៅតាមទម្រង់ច្បាប់[12]។ កត្តាដែលជះឥទ្ធិពលនាំអោយមានការប្តឹងមោឃៈភាពមាន២ចំណុច៖

- ការកោះហៅបុគ្គលគ្រប់រូបដោយមន្ត្រីនគរបាលយុត្តិធម៌គ្មានការជូនដំណឹងដល់ព្រះរាជអាជ្ញា[13]

ឧទាហរណ៍៖ ការកោះហៅបុគ្គលណាម្នាក់ដោយស្រេចតែចិត្ត និងគ្មានការអនុញ្ញាតពីថ្នាក់លើ

- ការកោះហៅបុគ្គលគ្រប់រូបដោយមន្ត្រីនគរបាលយុត្តិធម៌មានការបង្ខំរូបរាងកាយ[14]

---

10 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩២និងមាត្រា១០៩

11 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៣និងមាត្រា១០៩

12 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៤និងមាត្រា១០៩

13 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៤ កថាខណ្ឌទី២ និងមាត្រា១០៩

14 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១៩៦៦)(ចូលជាធរមានជាសកលឆ្នាំ១៩៧៦ និងនៅកម្ពុជាឆ្នាំ១៩៩២)មាត្រា៧ និង 14 ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ មាត្រា២១៧

ឧទាហរណ៍៖ ការប្រើកម្លាំងវាយបុគ្គលណាម្នាក់ដើម្បី អោយចូលខ្លួនស្តាប់ចម្លើយ

ជាចុងក្រោយយោងតាមចំណុចខាងលើ គឺជាមូលហេតុដែលនាំឲ្យកើតមានមោឃៈភាព បទបញ្ញាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង។

### ១.១.៦ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ

ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រគឺ សំដៅទៅលើការជួយដល់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ម្យ៉ាងទៀតមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការពឹងដល់បុគ្គលគ្រប់រូបដែលមានជំនាញ ដើម្បីជួយស្វែងរកភស្តុតាង និងបញ្ជាក់ពីការពិត[15]។ មូលហេតុដែលនាំឲ្យមានមោឃៈភាពមាន ២ ចំណុច៖

1. មន្ត្រីនគរបាលយុត្តិធម៌ មិនបានពឹងដល់បុគ្គល ដែលមានជំនាញមកជួយរកភស្តុតាង។

ឧទាហរណ៍៖ ការពិនិត្យស្នាមក្រយ៉ៅដៃជនល្មើសទៅលើភស្តុតាងដែលមាន។

2. មន្ត្រីនគរបាលយុត្តិធម៌ មិនអនុញ្ញាតដល់បុគ្គល ដែលមានជំនាញធ្វើការពិនិត្យ។

ឧទាហរណ៍៖ ការមិនសហការរវាងមន្ត្រីនគរបាលជាមួយអ្នកជំនាញ។

### ១.១.៧ ការឃាត់ខ្លួន

នៅក្នុងអំឡុងពេលធ្វើការឃាត់ខ្លួន ប្រសិនបើការប្រព្រឹត្តបទល្មើសនោះគឺជាការប្រព្រឹត្តបទល្មើសជាក់ស្តែង ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនដោយមិនចាំបាច់ស្នើសុំដីកាពីព្រះរាជអាជ្ញា ឬមិនចាំបាច់មានដីកានោះឡើយ ក្នុងការចាប់ខ្លួនជនល្មើស ឬ ជនសង្ស័យនោះនៅហ្នឹងកន្លែង ប៉ុន្តែត្រូវមានការរាយការណ៍ជូនព្រះរាជអាជ្ញា[16]។ ប្រសិនបើបទល្មើសមិនជាក់ស្តែងនោះទេ នគរបាលយុត្តិធម៌ត្រូវតែធ្វើការស្នើសុំដីកាចាប់ខ្លួនទៅព្រះរាជអាជ្ញាដើម្បីសុំដីកាចេញចាប់ខ្លួនជនល្មើស ឬ ជនសង្ស័យនោះ។ បន្ទាប់ពីទទួលបានដីកាពីព្រះរាជអាជ្ញាហើយនោះ នគរបាលយុត្តិធម៌អាចធ្វើការចាប់ខ្លួនជនល្មើសរួចបញ្ជូនទៅកាន់ស្ថានីយនគរបាលយុត្តិធម៌ពាក់ព័ន្ធដើម្បីធ្វើការសាកសួរ និងរៀបចំកសាងសំណុំរឿងដើម្បីបញ្ជូនទៅកាន់តុលាការដើម្បីធ្វើការសាកសួរ និងសម្រេចតាមច្បាប់។

- រយៈពេលនៃការឃាត់ខ្លួន

នៅក្នុងដំណាក់កាលនៃការឃាត់ខ្លួននោះប្រសិនបើបទល្មើស ជាបទមជ្ឈិមគេត្រូវឃាត់ខ្លួនរយៈពេល ៤៨ ម៉ោង តែបើបទល្មើសជាបទឧក្រិដ្ឋត្រូវឃាត់ខ្លួនយ៉ាងយូរ៧២ម៉ោង។ នៅក្នុងដំណាក់កាលសាកសួរនៅនគរបាលយុត្តិធម៌នោះ ប្រសិនរកមិនឃើញមានបទល្មើស ឬ មិនមានភស្តុតាងនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវដោះលែង

[15] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៥និងមាត្រា១០៩

[16] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៦និងមាត្រា១០៩

ជនសង្ស័យនោះឲ្យមានសេរីភាពវិញបាន។ តែបើរកឃើញមានបទល្មើស ឬ មានភស្តុតាងគ្រប់គ្រាន់នោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវកសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការដើម្បីធ្វើតាមនីតិវិធីបន្ត។

នៅពេលបញ្ជូនទៅសាកសួរនៅតុលាការ ក្នុងករណីបើព្រះរាជអាជ្ញារកមិនឃើញនូវបទល្មើសនោះទេ ព្រះរាជអាជ្ញាត្រូវធ្វើការសម្រេច តម្កល់រឿងទុកឥតចាត់ការ និងដោះលែងជនសង្ស័យនោះឲ្យមានសេរីភាពវិញភ្លាម។ តែប្រសិនរកឃើញមាននូវតម្រុយនៃបទល្មើសនោះ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ជនសង្ស័យនោះ និងបញ្ជូនបន្តទៅចៅក្រមស៊ើបសួរដើម្បីសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃ ការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់បុគ្គលដែលសង្ស័យ ដែលបានចូលរួមនៅក្នុងបទល្មើស។ ក្នុងស្ថានភាពមួយទៀតដែលអាចឈានទៅរកការឃាត់ខ្លួននោះគឺ បុគ្គលដែលមិនព្រមសហការជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌ ហើយករណីនេះក៏អាចឃាត់ខ្លួនបុគ្គលដែលផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញៈ

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនទៅព្រះរាជអាជ្ញាព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននោះ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ ម៉ោង។ ថិរវេលាត្រូវគិតពីម៉ោងដែលសាមីខ្លួនមកដល់អគ្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។ ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយបង្ហាញឲ្យឃើញថាៈ មានពិរុទ្ធលើបុគ្គលដែលឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចពន្យាពេលការឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យាពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា។ ការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវដាក់បញ្ចូនទៅក្នុងសំណុំរឿង។

ការពន្យារគឺជាវិធានការពិសេស។ ការពន្យានេះមិនអាចឲ្យលើសពី ២៤ ម៉ោងឡើយដោយមិនគិតពីថិរវេលាចាំបាច់នៃការដឹកជញ្ជូន។

➢ មូលហេតុនាំអោយមានការប្តឹងស្នើសុំមោឃភាពនៃអំឡុងពេលឃាត់ខ្លួន អនីតិជន

ការពន្យារបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជនចំពោះបទឧក្រិដ្ឋ

ការឃាត់ខ្លួនអនីតិជនដែលមានអាយុពី ១៤ ដល់ក្រោម ១៦ ឆ្នាំ ហួសរយៈពេល ៣៦ ម៉ោង

ចំពោះបទមជ្ឈិម អនីតិជនមានអាយុ ១៤ ដល់ក្រោម ១៦ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោង។

ចំពោះបទឧក្រិដ្ឋអនីតិជនដែលមានអាយុពី ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោង។

ចំពោះបទមជ្ឈិមអនីតិជនមានអាយុ ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោង។

អនីតិជនមានអាយុក្រោម ១៤ ឆ្នាំត្រូវគេឃាត់ខ្លួន។

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយមន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួននោះដោយប្រាប់បានឲ្យដឹងពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់សាមីខ្លួនឲ្យបានដឹងផងដែរអំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ នៃក្រមនេះ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ។

➢ មូលហេតុនាំអោយមានការប្តឹងស្នើសុំមោឃភាពនៃអំឡុងពេលឃាត់ខ្លួន

– ការឃាត់ខ្លួនដោយលើសរយៈពេល ជាគោលការណ៍រយៈពេលដែលឃាត់ខ្លួននីតិជនមានរយៈពេល៤៨ម៉ោង( ២ថ្ងៃ ) ប៉ុន្តែអាចពន្យាបានលុះត្រាតែមានមូលហេតុសមស្រប និងអាចទទួលយកបាន ហើយស្នើនោះអាចថែមបាន២៤ម៉ោងទៀត( ១ថ្ងៃ ) ពោលគឺសរុបរួម៧២ម៉ោង បើសិនជាមានការឃាត់ខ្លួនហួសរយៈពេលលើសពីនេះវាជាការឃាត់ខ្លួនខុសច្បាប់។

### ១.១.៨ កំណត់ហេតុស្តីពីការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការប្រាប់មូលហេតុដល់ បុគ្គលគ្រប់រូបក្នុងករណីមានការឃាត់ខ្លួន ហើយត្រូវបានការបញ្ជាក់ពីមូលហេតុត្រឹមត្រូវ ។ មូលហេតុនាំអោយមានការមោឃៈភាពទាក់ទងទៅ និងកំណត់ហេតុស្តីពីការឃាត់ខ្លួនមាន២ចំនុចគឺ[17] ៖

➢ សកម្មភាពរបស់មន្ត្រីនគរបានយុត្តិធម៌ត្រូវធ្វើចំពោះជនឃាត់ខ្លួន[18]

– ការឃាត់ខ្លួនដោយមិនមានមូលហេតុសមស្រប[19]

– ការមិនពន្យល់អំពីសិទ្ធិរបស់ជនត្រូវឃាត់ខ្លួនមាន សិទ្ធិមានមេធាវី សិទ្ធិមានអ្នកបកប្រែ សិទ្ធិមិនឆ្លើយ សិទ្ធិទទួលបានការអានអំពីលិខិតមួលចំនួនចំពោះជនដែលមិនចេះអក្សរជាអាទិ៍។

➢ សកម្មភាពរបស់មន្ត្រីនគរបានយុត្តិធម៌ត្រូវធ្វើចំពោះទម្រង់ច្បាប់[20]

– ក្រោយពីធ្វើការឃាត់ខ្លួនរួច មន្ត្រីនគរបានយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន និងត្រូវគោរពតាមទម្រង់ដែលច្បាប់កំណត់។

ការធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដោយចុះសេចក្តីដូចតទៅៈ

– ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលមានបង្គាប់ឲ្យឃាត់ខ្លួន

– អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

17 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧និងមាត្រា១០៩

18 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧ វគ្គព្យ:ខណ្ឌ១និងមាត្រា១០៩

19 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១៩៦៦)(ចូលជាធរមានជាសកលឆ្នាំ១៩៧៦ និងនៅកម្ពុជាឆ្នាំ១៩៩២)មាត្រា៩

20 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧ វគ្គព្យ:ខណ្ឌ២និងមាត្រា១០៩

- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមចាប់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តិ[21]
- ជាយថាហេតុឈ្មោះអ្នកបកប្រែ។កំណត់ហេតុនេះត្រូវតែចុះហត្ថលេខា

**ចំណាំ** គ្មានអំពើហិង្សានោះឡើយ ក្នុងអំឡុងពេលធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន។

### ១.១.៩ ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

សិទ្ធិមានមេធាវី គឺជាកិច្ចនីតិវិធីដែលមានចែងនៅក្នុងច្បាប់កំពូលរបស់ជាតិ និងច្បាប់អន្តរជាតិនានា ដែលកម្ពុជា ទទួលស្គាល់។ សិទ្ធិមានមេធាវី ចាប់ផ្តើមមាននៅក្នុងអំឡុងពេលដែលជនណាម្នាក់ ត្រូវនគរបាលយុត្តិធម៌ឃាត់ខ្លួនជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស។ រដ្ឋធម្មនុញ្ញកម្ពុជា ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា រួមផ្សំជាមួយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការពារសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋកម្ពុជា។ សិទ្ធិទាំងនោះរួមមាន សិទ្ធិទទួលបានមេធាវីផងដែរ។ នៅក្នុងរបបប្រជាធិបតេយ្យដែលយកច្បាប់ជាធំ មេធាវីមានមុខងារសំខាន់ក្នុងការការពារជនសង្ស័យ ឬ ជនជាប់ចោទពីការរំលោភបំពានសិទ្ធិស្របច្បាប់របស់ពួកគេពីភ្នាក់ងាររដ្ឋ។ នេះជាយន្តការមួយដើម្បីបញ្ចៀសនូវអំពើរំលោភអំណាចរបស់អាជ្ញាធរមានសមត្ថកិច្ច។ ជារួមសិទ្ធិមានមេធាវី គឺជាការធានានូវតុល្យភាពរវាងការប្រើប្រាស់អំណាចរដ្ឋរបស់នគរបាល និងការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ពលរដ្ឋ ដែលជាប់សង្ស័យពីបទល្មើសណាមួយ។ មេធាវីមានតួនាទីធានាដល់ជនសង្ស័យនូវសិទ្ធិនានាដែលមានចែងក្នុងនីតិវិធីនៃច្បាប់របស់រដ្ឋ បន្ទាប់ពីនគរបាលយុត្តិធម៌ឃាត់ខ្លួន( ជនសង្ស័យ ឬជនជាប់ចោទ ) មិនយល់ពីច្បាប់ និងនីតិវិធីរបស់តុលាការទេ។ ជាក់ស្តែងគាត់ត្រូវការមេធាវីដើម្បីជួយ ព្រោះមេធាវីមានជំនាញខាងច្បាប់[22]។

ច្បាប់អនុញ្ញាតឲ្យជនដែលត្រូវនគរបាលឃាត់ខ្លួនមានសិទ្ធិនៅស្ងៀមស្ងាត់ មិនឆ្លើយតបទៅនឹងសំណួរទាំងឡាយរបស់នគរបាល។ មិនត្រឹមតែប៉ុណ្ណោះការឃាត់ខ្លួនជនសង្ស័យ នគរបាលអាចតាំងសំណួរ ហើយឲ្យជនសង្ស័យឆ្លើយ ប៉ុន្តែនគរបាលត្រូវប្រាប់ទៅជនសង្ស័យថា គាត់មានសិទ្ធិឆ្លើយក៏បាន មិនឆ្លើយក៏បាន ដោយរងចាំមេធាវីមកតំណាងការពារសិទ្ធិឲ្យខ្លួន។ ប៉ុន្តែបើជនសង្ស័យឆ្លើយចម្លើយរបស់គាត់ អាចត្រូវបាននគរបាលយកទៅប្រើដើម្បីដាក់បន្ទុកទៅលើជនសង្ស័យ។ ចំណុចនេះវត្តមានរបស់មេធាវីមានសារៈសំខាន់ផងដែរ ក្នុងការបញ្ចៀសការគាបសង្កត់ណាមួយពីសំណាក់នគរបាលទៅលើជនសង្ស័យ ឬជនជាប់ចោទ ដើម្បីធានានូវភាពត្រឹមត្រូវនៃការអនុវត្តនីតិវិធីច្បាប់ ករណីនគរបាលធ្វើអ្វីខុសច្បាប់ទៅលើជនសង្ស័យ។

---

21 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៨និងមាត្រា១០៩

22 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៨និងមាត្រា១០៩

ឧទាហរណ៍៖ គំរាមកំហែង ឬធ្វើទារុណកម្ម មេធាវីអាចប្តឹងនគរបាលទាំងនោះ។

ទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញខ្មែរ បានធានាការពារនូវជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋកម្ពុជា។ ការចោទប្រកាន់ ការចាប់ខ្លួន និងការឃាត់ខ្លួនជនណាម្នាក់ មិនទាន់អាចបញ្ជាក់បានថា ជនដែលត្រូវសមត្ថកិច្ចឃាត់ខ្លួននោះ ពិតជាមនុស្សប្រព្រឹត្តខុសច្បាប់ ឬ ជាជនល្មើសនោះឡើយ ដរាបណាតុលាការមិនទាន់ប្រកាសទោសចប់សព្វគ្រប់ទេនោះ។ ពិតប្រាកដណាស់ជនដែលត្រូវបានឃាត់ខ្លួននោះមានសិទ្ធិប្តឹងទៅលើចំណាត់ការខាងលើបាន[23] ករណីដែលមន្ត្រីនគរបានយុត្តិធម៌ធ្វើផ្ទុយនឹងច្បាប់។

### ១.១.១០ ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួនគឺ សំដៅទៅលើស្ថានភាពរបស់ជនដែលត្រូវបានឃាត់ខ្លួនតម្រូវឲ្យមានការទទួលបានការពិនិត្យ និងបញ្ជាក់អំពីស្ថានភាពសុខភាពជនដែលត្រូវបានឃាត់ខ្លួននោះ។

ក្នុងករណីដែលនេះកត្តានាំអោយមានការស្នើសុំមោយភាពត្រង់ចំនុចនេះគឺ មាន២ចំណុច[24]៖

1. នៅក្នុងអំឡុងពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនមិនបានផ្តល់ជំនួយគ្រូពេទ្យដល់ជនដែលត្រូវបានឃាត់ខ្លួន ( មានការស្នើសុំពីជនត្រូវឃាត់ខ្លួន )

ឧទាហរណ៍៖ មានការស្នើសុំពីជនឃាត់ខ្លួនហើយ តែមន្ត្រីនគរបាលយុត្តិធម៌មិនអើពើ។

2. ករណីជនដែលត្រូវបានឃាត់ខ្លួនមានការបញ្ជាក់អំពីសុខភាពពីគ្រូពេទ្យជំនាញរួចហើយ ( ឧទាហរណ៍ ជម្ងឺគាំងបេះដូង ជម្ងឺក្រលាន ) តែមន្ត្រីនគរបាលនៅតែឃាត់ខ្លួនដោយមិនមានសំអាងច្បាស់លាស់។

### ១.១.១១ អនីតិជនដែលត្រូវបានឃាត់ខ្លួន

ជាការពិតណាស់យោងតាមស្មារតីនៃច្បាប់ស្តីពីអនីតិជនមិនត្រូវបានអនុញ្ញាតអោយមានការឃាត់ខ្លួនឡើយ ព្រោះជាការគោរពដល់សិទ្ធិកុមារ និងស្មារតីអនីតិជននោះ ប៉ុន្តែការឃាត់ខ្លួនអាចធ្វើទៅបានដោយចាប់គិតលើអាយុរបស់អនីតិជននោះ[25]៖

1. ការឃាត់ខ្លួនអនីតិជនដែលមានអាយុពី ១៤ ដល់ក្រោម ១៦ ឆ្នាំ ហួសរយៈពេល ៣៦ ម៉ោង
2. ចំពោះបទមជ្ឈិម អនីតិជនមានអាយុ ១៤ ដល់ក្រោម ១៦ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោង។

---

[23] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៨និងមាត្រា១០៩

[24] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៩និងមាត្រា១០៩

[25] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០០និងមាត្រា១០៩

3. ចំពោះបទឧក្រិដ្ឋអនីតិជនដែលមានអាយុពី ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោង។
4. ចំពោះបទមជ្ឈិមអនីតិជនមានអាយុ ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោង។
5. អនីតិជនមានអាយុក្រោម ១៤ ឆ្នាំត្រូវគេឃាត់ខ្លួន។

### ១.១.១២ ការហាមឃាត់មិនឲ្យស្តាប់ដោយឯង ជាអាទិ៍

ការស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការប្រមូល និងស្វែងរកភស្តុតាងក្រោមរូបភាពស្របច្បាប់ និងត្រឹមត្រូវ។ ការប្រើប្រាស់អំណាចក្នុងការប្រមូលភស្តុតាងអាចជា មូលហេតុក្នុងការប្តឹងសុំមោឃៈភាព។ ការលួចស្តាប់ដោយឯកឯង ដោយមិនមានការអនុញ្ញាត គឺជាការបំពានសិទ្ធិឯកជនក្នុងការរស់នៅ ហើយការបំពាននៅស្ថានភាពបែបនេះ ច្បាប់ផ្តល់សិទ្ធិអោយមានការប្តឹងដើម្បីសុំធ្វើមោឃភាពនៃកិច្ចនេះ ការហាមឃាត់នោះមានដូចជា[26]៖

- មន្ត្រីនគរបាលយុត្តិធម៌ពុំអាចបង្គាប់ឱ្យស្តាប់ ឬ ថតសំឡេងការសន្ទនាតាមទូរស័ព្ទឡើយ
- មន្ត្រីនគរបាលយុត្តិធម៌ពុំអាចអំណាចបង្គាប់ឲ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរស័ព្ទ ឬ សារតាមអ៊ីនធើណេត

### ១.១.១៣ ថិរពេលានៃការស៊ើបអង្កេតករណីជាក់ស្តែង

ថិរពេលានៃការស៊ើបអង្កេតករណីជាក់ស្តែង គឺជាពេលវេលាមួយដល់សំខាន់សម្រាប់ការបើកស៊ើបអង្កេត និងប្រមូលភស្តុតាង។ គួរកត់សម្គាល់មិនមែនអំណាចនៃការស៊ើបអង្កេតជាក់ស្តែងទេ ដែលមានការអនុញ្ញាតឲ្យនគរបាលយុត្តិធម៌លើកឡើងអំពីភាពជាក់ស្តែងនៃបទល្មើស ក៏ប៉ុន្តែដោយសារតែស្ថានភាពជាក់ស្តែងទេ ដែលអនុញ្ញាតឲ្យនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចស៊ើបអង្កេតជាក់ស្តែង[27]។ ឧទាហរណ៍៖ ការឆែកឆេរមិនអាចត្រូវបានអនុញ្ញាតឲ្យធ្វើដើម្បីស្វែងរកបទល្មើសជាក់ស្តែងនោះទេ គឺបទល្មើសជាក់ស្តែងនាំឲ្យមានការឆែកឆេររកភស្តុតាង។ ដូចគ្នាដែរ ការចាប់ខ្លួនជនល្មើសដោយរាល់បុគ្គល ឬដោយមន្ត្រីនគរបាលយុត្តិធម៌ដោយមិនបាច់មានដីកាពីតុលាការជាដើមអាចធ្វើបាន បើកាលណាមានបទល្មើសជាក់ស្តែង។ ជាការពិតណាស់ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងគឺសំដៅទៅលើការការពាររបង្ក និងស្តារឡើងវិញឲ្យឆាប់រហ័សនូវការខូចខាតនៃសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិអាយុជីវិតមនុស្ស ទ្រព្យសម្បត្តិដែលបង្កឡើងដោយបទល្មើសជាពិសេសដើម្បីធានាដល់ការប្រមូលភស្តុតាងឲ្យបានឆាប់រហ័សប្រកបទៅដោយប្រសិទ្ធិភាពការប្រមូលភស្តុតាងជាក់ស្តែងធ្វើឡើងតាមរយៈជា បុគ្គលគ្រប់រូបមានសិទ្ធិស្របច្បាប់ក្នុងការ ចាប់ខ្លួនជនល្មើសរួចប្រគល់ឲ្យមន្ត្រី

[26] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៥និងមាត្រា១០៩
[27] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៦

នគរបាលយុត្តិធម៌ដែលនៅជិតបំផុត ក្រុមដេញ ការឃាត់ខ្លួននូវបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ឬចូលរួមប្រព្រឹត្តបទល្មើស ឬបុគ្គលដែលដឹងព័ត៌មានពីបទល្មើសតែប្រកែកមិនព្រមផ្តល់ព័ត៌មាន ដើម្បីសួរចម្លើយ រួចប្រមូលព័ត៌មានទាក់ទងជាមួយនឹងបទល្មើស ឬការឆែកឆេរលំនៅឋានដោយគ្រាន់តែទទួលការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះដោយផ្ទាល់មាត់ក៏ដោយតែមិនចាំបាច់ទទួលការអនុញ្ញាតពីប្រធានសាលាដំបូងនោះទេ។ ចំនុចនេះសុទ្ធសឹងជាអនុភាពពេលនៃការស៊ើបអង្កេតករណីជាក់ស្តែង ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការស៊ើបអង្កេតខុសចិរវេលានោះ នាំអោយមានការលើកឡើងថា កិច្ចនីតិវិធីនេះជាកិច្ចនីតិវិធីខុសច្បាប់។

### ១.១.១៤ និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ

និទ្ទេសដែលត្រូវបានចុះនៅក្នុងកំណត់ហេតុ គឺជាឯកសារចម្បងមួយដែលត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ឬ ជាកំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងទម្រង់បែបបទដែលច្បាប់បានកំណត់ ទន្ទឹមនឹងនេះផងដែរ កំណត់ហេតុនេះត្រូវមានគឺមានឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តធម៌ អង្គភាពរបស់មន្ត្រីនោះ កាលបរិច្ឆេទនៃទំព័រទាំងអស់ត្រូវមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តធម៌ ពាក្យឆូតលុប ឬ ការយល់ព្រមត្រូវបានមានបញ្ជាក់យល់ព្រមដែលចុះហត្ថលេខារបស់នគរបាលយុត្តិធម៌[28]។ កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬ ស្តីពីការឃាត់ខ្លួនត្រូវមានការចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ។ នៅក្នុងចំណុចនេះគឺជាចំណុចសំខាន់មួយដែលត្រូវធ្វើការគោរពជាលក្ខណៈដាច់ខាត់ បើពុំដូច្នេះទេកិច្ចនីតិវិធីនេះចាត់ទុកថាធ្វើផ្ទុយនឹងច្បាប់ដែលមានជាធរមាន។

## ១.២ កិច្ចនីតិវិធីក្នុងការស៊ើបអង្កេតបឋម

ទាក់ទងជាមួយនឹងចំនុចពិសេសនៃមូលហេតុនាំឲ្យកើតមានមោឃៈភាពនៅក្នុងការស៊ើបអង្កេតជាក់ស្តែង[29]។ មូលហេតុនាំឲ្យកើតមានមោឃៈភាពក្នុងការស៊ើបសង្កេតបឋមក៏មិនខុសគ្នាប៉ុន្មានដែរពោល[30] គឺមានច្បាប់កំណត់ច្បាស់លាស់ និងអត្ថន័យមានសភាពដូចគ្នាក្នុងបទបញ្ញត្តិមួយចំនួន ហើយវិធានមោឃៈភាពនេះជាប្រភេទ វិធានបទបញ្ញត្តិមានលក្ខណៈដាច់ខាតត្រូវតែគោរពតាមដូចគ្នាផងដែរ។ ដោយហេតុនេះមូលហេតុនាំឲ្យមានមោឃភាពនៃការស៊ើបអង្កេតបឋមមានចំនួន៧មាត្រា ជាក់ស្តែងណាស់នៅក្នុងចំណុចការស៊ើបសង្កេតបឋមមានចំនុចខ្លះដូចគ្នា ទៅនិងការស៊ើបអង្កេតបឋម ( ការឃាត់ខ្លួន[31] កំណត់ហេតុស្តីពីការឃាត់ខ្លួន[32] អនីតិ

28 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៨

29 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៩

30 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១១៧

31 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៦ និងមាត្រា១១៧

32 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧ និងមាត្រា១១៧

ជនដែលត្រូវបានឃាត់ខ្លួន[33] ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯងជាអាទិ៍[34] ការបញ្ជាឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម[35] ) និងមានចំណុចខ្លះមិនដូចគ្នាទៅ និងការស៊ើបអង្កេតបឋម ( ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា[36] ការឆែកឆេរ[37] )។ទន្ទឹមនឹងនេះចំនុចដែលខុសគ្នារវាងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមមានៈ

### ១.២.១ ការឃាត់ខ្លួន

ការឃាត់ខ្លួនប្រសិនការប្រព្រឹត្តបទល្មើសនោះ គឺជាការប្រព្រឹត្តជាក់ស្តែងគឺ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនដោយមិនចាំបាច់ស្នើសុំដីកាពីព្រះរាជអាជ្ញានោះឡើយ ក្នុងករណីការចាប់ខ្លួនជនល្មើស ឬ ជនសង្ស័យនោះនៅហ្នឹងកន្លែងជាក់ស្តែងតែម្តង ប៉ុន្តែត្រូវមានការរាយការណ៍ជូនព្រះរាជអាជ្ញា[38]។ តែបើបទល្មើសមិនជាក់ស្តែងនោះសមត្ថកិច្ចនគរបាលយុត្តិធម៌ត្រូវតែស្នើសុំដីកាចាប់ខ្លួនទៅព្រះរាជអាជ្ញាដើម្បីសុំដីកាចេញចាប់ខ្លួនជនល្មើស ឬ ជនសង្ស័យនោះ។ បន្ទាប់ពីទទួលបានដីកាពីព្រះរាជអាជ្ញាហើយនោះសមត្ថកិច្ចនគរបាលយុត្តិធម៌ចាប់ខ្លួនជនល្មើសបញ្ជូនទៅកាន់ស្នាក់ការនគរបាលយុត្តិធម៌ពាក់ព័ន្ធដើម្បីធ្វើការសាកសួរ និងរៀបចំកសាងសំណុំរឿងដើម្បីបញ្ជូនទៅកាន់តុលាការដើម្បីធ្វើការសាកសួរ និងសម្រេចតាមច្បាប់។

– រយៈពេលនៃការឃាត់ខ្លួន

នៅក្នុងដំណាក់កាលឃាត់ខ្លួននោះប្រសិនបើបទល្មើស ជាបទមជ្ឈិមគេត្រូវឃាត់ខ្លួនរយៈពេល ៤៨ ម៉ោង តែបើបទឧក្រិដ្ឋត្រូវឃាត់ខ្លួនយ៉ាងយូរ ៧២ ម៉ោង។ នៅក្នុងដំណាក់កាលសាកសួរនៅនគរបាលយុត្តិធម៌នោះប្រសិនរកមិនឃើញមានបទល្មើស ឬមិនមានភស្តុតាងនោះសមត្ថកិច្ចនគរបាលយុត្តិធម៌អាចសម្រេចដោះលែងជនសង្ស័យនោះឲ្យមានសេរីភាពវិញបាន។ តែបើរកឃើញមានបទល្មើស ឬ មានភស្តុតាងគ្រប់គ្រាន់នោះត្រូវកសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការដើម្បីសម្រេច។ នៅពេលបញ្ជូនទៅសាកសួរនៅតុលាការប្រសិនបើព្រះរាជអាជ្ញារកមិនឃើញនូវបទល្មើសនោះទេ ព្រះរាជអាជ្ញាត្រូវសម្រេចមិនចោទប្រកាន់ និងដោះលែងជនសង្ស័យនោះឲ្យមានសេរីភាពវិញភ្លាម។ តែប្រសិនរកឃើញមាននូវតម្រុយនៃបទល្មើសនោះព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ជនសង្ស័យនោះ និងបញ្ជូនបន្តទៅចៅក្រមស៊ើបសួរដើម្បីសម្រេចឃុំខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់បុគ្គលដែលសង្ស័យ ដែលបានចូលរួមនៅក្នុងបទ

[33] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០០ និងមាត្រា១១៧
[34] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៥ និងមាត្រា១១៧
[35] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១១៤ និងមាត្រា១១៧
[36] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៧ និងមាត្រា១១៧
[37] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១១៣ និងមាត្រា១១៧
[38] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៦និងមាត្រា១០៩

ល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញះ

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនទៅព្រះរាជអាជ្ញាព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននោះ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ ម៉ោង។ ថិរវេលាត្រូវគិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។ ចំពោះបទឧក្រិដ្ឋកាលណាមានតម្រុយបង្ហាញឲ្យឃើញថាះ មានពិរុទ្ធលើបុគ្គលដែលឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចពន្យារការឃាត់ខ្លួនបានប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យានេះត្រូវសុំទៅព្រះរាជអាជ្ញា។ ការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រឹមត្រូវដាក់បញ្ជូនទៅក្នុងសំណុំរឿង។

ការពន្យា គឺជាវិធានការពិសេស។ ការពន្យានេះមិនអាចឲ្យលើសពី ២៤ ម៉ោងឡើយដោយមិនគិតពីថិរវេលាចាំចាច់នៃការដឹកជញ្ជូន។

➢ មូលហេតុនាំអោយមានការប្តឹងស្នើសុំមោឃភាពនៃអំឡុងពេលឃាត់ខ្លួន អនីតិជន

ការពន្យាបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជនចំពោះបទឧក្រិដ្ឋ

ការឃាត់ខ្លួនអនីតិជនដែលមានអាយុពី ១៤ ដល់ក្រោម ១៦ ឆ្នាំ ហួសរយៈពេល ៣៦ ម៉ោង

ចំពោះបទមជ្ឈិម អនីតិជនមានអាយុ ១៤ ដល់ក្រោម ១៦ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោង។

ចំពោះបទឧក្រិដ្ឋអនីតិជនដែលមានអាយុពី ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោង។

ចំពោះបទមជ្ឈិមអនីតិជនមានអាយុ ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោង។

អនីតិជនមានអាយុក្រោម ១៤ ឆ្នាំត្រូវគេឃាត់ខ្លួន។

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយមន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួននោះដោយប្រាប់បានឲ្យដឹងពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់សាមីខ្លួនឲ្យបានដឹងផងដែរអំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ នៃក្រមនេះ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ។

➢ មូលហេតុនាំអោយមានការប្តឹងស្នើសុំមោឃភាពនៃអំឡុងពេលឃាត់ខ្លួន

- ការឃាត់ខ្លួនដោយលើសរយៈពេល ជាគោលការណ៍រយៈពេលដែលឃាត់ខ្លួននីតិជនមានរយៈពេល ៤៨ម៉ោង( ២ថ្ងៃ ) ប៉ុន្តែអាចពន្យារបានលុះត្រាតែមានមូលហេតុសមស្រប និងអាចទទួលយកបាន

ហើយស្នើរនោះអាចថែមបាន២៤ម៉ោងទៀត( ១ថ្ងៃ ) ពោលគឺសរុបរួម៧២ម៉ោង បើសិនជាមានការឃាត់ខ្លួនហួសរយៈពេលលើសពីនេះវាជាការឃាត់ខ្លួនខុសច្បាប់។

### ១.២.២ កំណត់ហេតុស្ដីពីការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការប្រាប់ដល់ដល់បុគ្គល់គ្រប់រូបក្នុងករណីមានការឃាត់ខ្លួន ហើយត្រូវបានការបញ្ជាក់ពីមូលហេតុត្រឹមត្រូវ ។ មូលហេតុនាំអោយមានការមោឃភាពទាក់ទងទៅ និងកំណត់ហេតុស្ដីពីការឃាត់ខ្លួនមាន២ចំនុចគឺ[39] ៖

- ➢ សកម្មភាពរបស់មន្ត្រីនគរបានយុត្តិធម៌ត្រូវធ្វើចំពោះជនឃាត់ខ្លួន[40]
- – ការឃាត់ខ្លួនដោយមិនមានមូលហេតុសមស្រប[41]
- – ការមិនពន្យល់អំពីសិទ្ធិរបស់ជនត្រូវឃាត់ខ្លួនមាន សិទ្ធិមានមេធាវី សិទ្ធិមានអ្នកបកប្រែ សិទ្ធិមិនឆ្លើយ សិទ្ធិទទួលបានការអានអំពីលិខិតមួលចំនួនចំពោះជនដែលមិនចេះអក្សរជាអាទិ៍។
- ➢ សកម្មភាពរបស់មន្ត្រីនគរបានយុត្តិធម៌ត្រូវធ្វើចំពោះទម្រង់ច្បាប់[42]
- – ក្រោយពីធ្វើការឃាត់ខ្លួនរួច មន្ត្រីនគរបានយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួន និងត្រូវគោរពតាមទម្រង់ដែលច្បាប់កំណត់។

ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួនជាបន្ទាន់ដោយចុះសេចក្ដីដូចតទៅះ

- – ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលមានបង្គាប់ឲ្យឃាត់ខ្លួន
- – អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- – មូលហេតុនៃការឃាត់ខ្លួន
- – ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមចាប់ខ្លួន
- – ការឲ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តិ[43]
- – ជាយថាហេតុឈ្មោះអ្នកបកប្រែ។កំណត់ហេតុនេះត្រូវតែចុះហត្ថលេខា

**<u>ចំណាំ</u>** គ្មានអំពើហឹង្សានោះឡើង ក្នុងអំឡុងពេលធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួន។

---

[39] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧និងមាត្រា១០៩

[40] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧ វគ្គព្យ:ខណ្ឌ១និងមាត្រា១០៩

[41] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១៩៦៦)(ចូលជាធរមានជាសកលឆ្នាំ១៩៧៦ និងនៅកម្ពុជាឆ្នាំ១៩៩២)មាត្រា៩

[42] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៧ វគ្គព្យ:ខណ្ឌ២និងមាត្រា១០៩

[43] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៨និងមាត្រា១០៩

### ១.២.៣ អនីតិជនដែលត្រូវបានឃាត់ខ្លួន

ជាការពិតណាស់យោងតាមស្មារតីច្បាប់អនីតិជនមិនត្រូវបានអនុញ្ញាតអោយមានការឃាត់ខ្លួនឡើយ ព្រោះជាការគោរពដល់សិទ្ធិកុមារ និង ស្មារតីអនីតិជននោះ ប៉ុន្តែការឃាត់ខ្លួនអាចធ្វើទៅបានដោយចាប់គិតលើអាយុរបស់អនីតិជននោះ[44]៖

6. ការឃាត់ខ្លួនអនីតិជនដែលមានអាយុពី ១៤ ដល់ក្រោម ១៦ ឆ្នាំ ហួសរយៈពេល ៣៦ ម៉ោង
7. ចំពោះបទមជ្ឈិម អនីតិជនមានអាយុ ១៤ ដល់ក្រោម ១៦ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោង។
8. ចំពោះបទឧក្រិដ្ឋអនីតិជនដែលមានអាយុពី ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោង។
9. ចំពោះបទមជ្ឈិមអនីតិជនមានអាយុ ១៦ ដល់ក្រោម ១៨ ឆ្នាំ ឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោង។
10. អនីតិជនមានអាយុក្រោម ១៤ ឆ្នាំមិនត្រូវគេឃាត់ខ្លួន។

### ១.២.៤ ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទ៍

ការស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការប្រមូល និងស្វែងរកភស្តុតាងក្រោមរូបភាពស្របច្បាប់ និងត្រឹមត្រូវ។ ការប្រើប្រាស់អំណាចក្នុងការប្រមូលភស្តុតាងអាចជា មូលហេតុក្នុងការប្តឹងសុំមោឃៈភាព។ ការលួចស្តាប់ដោយឯកឯង ដោយមិនមានការអនុញ្ញាត គឺជាការបំពានសិទ្ធិឯកជនក្នុងការរស់នៅ ហើយការបំពាននៅស្ថានភាពបែបនេះ ច្បាប់ផ្តល់សិទ្ធិអោយមានការប្តឹងដើម្បីសុំធ្វើមោឃៈភាពនៃកិច្ចនេះ ការហាមឃាត់នោះមានដូចជា[45]៖

- មន្ត្រីនគរបាលយុត្តិធម៌ពុំអាចបង្គាប់ឱ្យស្តាប់ ឬ ថតសំឡេងការសន្ទនាតាមទូរស័ព្ទឡើយ
- មន្ត្រីនគរបាលយុត្តិធម៌ពុំអាចអំណាចបង្គាប់ឲ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរស័ព្ទ ឬ សារតាមអ៊ីនធើណេត

### ១.២.៥ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា សំដៅទៅលើការកិច្ចនីតិវិធីនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបញ្ចប់ ហើយទន្ទឹមនឹងនោះមន្ត្រីត្រូវបញ្ជូនកំណត់ហេតុ និងជនល្មើសទៅព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់ទៅតាមផ្លូវច្បាប់ដែលបានកំណត់។ ជាក់ស្តែងណាស់មូលហេតុដែលនាំអោយមានការប្តឹងមោឃៈភាពនៅកិច្ចនីតិវិធី ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញានេះមានដូចជា៖

---

44 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០០និងមាត្រា១០៩

45 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៥និងមាត្រា១០៩

- ក្រោយពីបញ្ចប់ការស៊ើបអង្កេតមន្ត្រីនគរបាលមិនបានបញ្ជូនកំណត់ហេតុ និងវត្ថុតាងទៅព្រះរាជអាជ្ញាអមជាមួយនិងជនល្មើស។
- ភស្តុតាងពាក់ព័ន្ធនឹងជនល្មើសមានភាពមិនប្រក្រតី[46]

### ១.២.៦ ការឆែកឆេរ

ការស៊ើបអង្កេតបឋមអាចដំណើរការបានដោយមានការផ្តួចផ្តើមរបស់មន្ត្រីនគរបាលយុត្តធម៌ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីដែលកើតមានបទឧក្រិដ្ឋ មជ្ឈិម ឬ បទលហុ។ ការស៊ើបអង្កេតបឋមដំណើរការ នៅក្នុងករណីបទឧក្រិដ្ឋ បទមជ្ឈិម នឹងមិនជាក់ស្តែងកន្លងផុតដោយច្បាប់កំណត់រយៈពេល៧ថ្ងៃប៉ុណ្ណោះគិតពីថ្ងៃប្រព្រឹត្តបទល្មើស។ អំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម មានលក្ខណៈប្រហាក់ប្រហែលនឹងអំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែងដោយគ្រាន់តែបទបញ្ញត្តិយោងតាមភាពខុសគ្នា។ រវាងទាក់ទងទៅនឹងការស៊ើបអង្កេតបឋមមាន[47] ចំណុចដែលខុសប្លែកគ្នាខ្លាំងគឺ ចំណុចទាក់ទងទៅនឹងអំណាចនៃការឆែកឆេរ[48]។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ ឬ ព្រះរាជអាជ្ញាប្រព្រឹត្តកំហុសនាំអោយមានមោឃៈភាពនៃការមិនគោរពវិធានបញ្ញត្តិការឆែកឆេរបាន មានលក្ខខណ្ឌដូចខាងក្រោម

1. ការយល់ព្រមដោយមិនមានលាយលក្ខណ៍អក្សរ ឬគ្មានការសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។
2. អ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ ហើយគ្មានការសរសេរឲ្យបានច្បាស់លាស់ និងកំណត់ហេតុថាអ្នកកាន់កាប់ទីកន្លែងនោះម្ចាស់យល់ព្រមឲ្យការឆែកឆេរ។
3. ករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬ បដិសេធការឆែកឆេរ ដោយមិនមានដីកាអនុញ្ញាតឲ្យឆែកឆេរពីប្រធានសាលាដំបូង
4. ការអនុវត្តនៃការឆែកឆេរអវត្តមានព្រះរាជអាជ្ញា
5. ការឆែកឆេរត្រូវធ្វើឡើងមិនចំពោះមុខអ្នកកាន់កាប់ទីកន្លែង
6. ការឆែកឆេរដោយគ្មានសាក្សី។
7. សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា សាក្សីមានសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ ឬជាកងរាជអាវុធហត្ថដែលជាកម្លាំងរួមធ្វើការប្រតិបត្តិ
8. ការឆែកឆេរបំពានថេរវេលាច្បាប់កំណត់ផ្តើមមុនម៉ោង៦ព្រឹក និងធ្វើហួសម៉ោង៦ល្ងាច។

---

46 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩២

47 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១១១ ដល់មាត្រា ១១៧

48 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១១៣និងមាត្រា១១៧

### ១.២.៧ ការបញ្ជាឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម

បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសអង្កេតបឋមគឺ ជាការកោះហៅបុគ្គលគ្រប់រូបដែលមន្ត្រីនគរបាលយុត្តិធម៌យល់ឃើញថា អាចមានពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតបទល្មើស។ យ៉ាងណាមិញ បទបញ្ជាឲ្យចូលខ្លួនត្រូវមានការគោរពទៅតាមទម្រង់ច្បាប់[49]។

កត្តាដែលជះឥទ្ធិពលនាំអោយមានការប្តឹងមោឃៈភាពមាន ២ ចំណុចៈ

- ការកោះហៅបុគ្គលគ្រប់រូបដោយមន្ត្រីនគរបាលយុត្តិធម៌ គ្មានការជូនដំណឹងដល់ព្រះរាជអាជ្ញា[50]

ឧទាហរណ៍ៈ ការកោះហៅបុគ្គលណាម្នាក់ដោយស្រេចតែ និងគ្មានការអនុញ្ញាតពីថ្នាក់លើ

- ការកោះហៅបុគ្គលគ្រប់រូបដោយមន្ត្រីនគរបាលយុត្តិធម៌មានការបង្ខំរូបរាងកាយ[51]

  ឧទាហរណ៍ៈ ការប្រើកម្លាំងវាយបុគ្គលណាម្នាក់ដើម្បី ឲ្យចូលខ្លួនស្តាប់ចម្លើយ

ជាចុងក្រោយពីរចំណុចខាងលើ គឺជាមូលហេតុដែលនាំឲ្យកើតមានមោឃៈភាព បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង។

## កថាខណ្ឌ២ មោឃៈភាពក្នុងដំណាក់កាលស៊ើបសួរ

មុននឹងឈានដល់ការបកស្រាយមោឃៈភាពដំណាក់កាលស៊ើបសួរអោយបានក្បោះក្បាយ គួរគប្បីត្រូវស្វែងយល់នៅពាក្យគន្លឹះជាមុនសិន។ មោឃៈភាពនៃការស៊ើបសួរមានន័យថា ការស៊ើបសួរដែលមិនគោរពទៅតាមច្បាប់។ ជាក់ស្តែងណាស់ កត្តាដែលនាំឲ្យមានមោឃៈភាពគឺជា ការបំពានវិធាន ឬ ទម្រង់ការសំខាន់ណាមួយ ដែលចែងដោយក្រមនេះ ឬ បទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការ ដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន។ ម៉្យាងទៀត មោឃភាពនៃការស៊ើបសួរជាការធ្វើឡើងដោយចៅក្រមស៊ើបសួរដែលទទួលបន្ទុក ប៉ុន្តែការប្រព្រឹត្តទៅហាក់ប្បីមានភាពមិនប្រក្រតី ឬ មិនត្រឹមត្រូវទៅតាមបទប្បញ្ញាត្តិច្បាប់ដែលបានកំណត់។ មូលហេតុដែលនាំអោយមានការមោឃភាពនៃការស៊ើបសួរមានច្រើនអាចមានដូចជាៈ ឯកសារយោង

- ការបានចម្លើយមកតាមការបង្ខិតបង្ខំ
- ការបានចម្លើយមកដោយសារតែការមិនគោរពតាមវិធានឬ នីតិវិធីនៃការសាកសួរ
- ការធ្វើទារុណកម្ម ឬក៏ការប្រើមធ្យោបាយខុសពីការកំណត់របស់ច្បាប់

49 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៨និងមាត្រា១០៩

50 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៩៤ កថាខណ្ឌទី២ និងមាត្រា១០៩

51 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១៩៦៦)(ចូលជាធរមានជាសកលឆ្នាំ១៩៧៦ និងនៅកម្ពុជាឆ្នាំ១៩៩២)មាត្រា៧ និង 51 ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ មាត្រា២១៧

ដូចនេះ ការស៊ើបសួរដែលទទួលបានចម្លើយ និង ភស្តុតាងបែបហ្នឹង គឺចាត់ទុកជា មោឃៈ ឬ មោឃៈភាព ព្រោះវាបានផ្ទុយទៅនឹងគោលការណ៍គ្រឹះនៃច្បាប់និង វិធានដែលច្បាប់បានកំណត់។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៥២ មោឃៈភាពនៃការមិនគោរព វិធានបញ្ញត្តិ បានចែងថា វិធាន និងទម្រង់ដែលចែងដោយមាត្រាខាងក្រោម ស្តីអំពីបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរមានលក្ខណៈដាច់ខាតនេះត្រូវតែគោរពតាម បើពុំដូច្នោះទេ នាំឲ្យមានមោឃៈភាពនៃនីតិវិធីដូចខាងក្រោម៖

**១.១ កិច្ចនីតិវិធីក្នុងដំណាក់កាលស៊ើបសួរ**

ជាការពិតណាស់ ចៅក្រមស៊ើបសួរមានតួនាទី បំពេញកិច្ចស៊ើបសួរទាំងដោះបន្ទុក និង ដាក់បន្ទុក[52]។ ទន្ទឹមនិងនេះ ការស៊ើបសួរគ្រប់នីតិវិធីច្បាប់តម្រូវអោយមានវត្តមានក្រឡាបញ្ជី ដើម្បីមានភាពងាយស្រួលក្នុងការកត់ត្រាគ្រប់សកម្មភាពនៃការស៊ើបសួរ[53]។ ក្នុងករណីនេះចៅក្រមស៊ើបសួរក៏ត្រូវគោរពទៅតាមដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនតាំងនៅ[54]។ ភ្ជាប់គ្នានេះ ចៅក្រមស៊ើបសួរអាចតាំងខ្លួនជាដើម្បីបណ្តឹងរដ្ឋប្បវេណីតាមពាក្យស្នើសុំរបស់ជនរងគ្រោះតាមការគួរ[55]។ ជាក់ស្តែងណាស់ ដើម្បីធានាដល់កិច្ចនីតិវិធីដើរលូន ចៅស៊ើបសួរអាចប្រើប្រាស់វិធានការនិរន្តរាយតាមការគួរ នៃសកម្មភាពក្នុងកិច្ចនីតិវិធីដែលខ្លួនកំពុងបំពេញ។ វិធាននិរន្តរាយគឺជាវិធានមួយដែលច្បាប់ផ្តល់សិទ្ធិអំណាចដល់ ចៅក្រមស៊ើបសួរប្រើប្រាស់ទៅតាមស្ថានភាពជាក់ស្តែងដែលកំពុងកើតមាន។ វិធាននិរន្តរាយចែកចេញជា៤[56]៖ ដីកាបង្គាប់អោយចូលខ្លួន ដីកាបង្គាប់អោយនាំខ្លួន ដីកាបង្គាប់អោយចាប់ខ្លួន ដីកាបង្គាប់អោយឃុំខ្លួន។ ដីកានីមួយៗមានសារៈសំខាន់ និងមុខងារខុសៗគ្នាហើយច្បាប់ក៏តម្រូវអោយមានការប្រើប្រាស់ដោយប្រុងប្រយ័ត្នផងដែរ។ រាល់ការប្រើប្រាស់ដីកានីមួយៗត្រូវមានតាមលំដាប់លំដោយ និងតាមស្ថានភាពការងារ។ ជាចុងបញ្ចប់ ដីកាដំណោះស្រាយដែលចៅក្រមស៊ើបសួរបានបំពេញតួនាទីចប់សព្វគ្រប់ ការចេញដីកាដំណោះស្រាយនេះចៅក្រមស៊ើបសួរមានជម្រើសពីរគឺ[57] ទីមួយចេញពីការដោះស្រាយលើកលែងចោទប្រកាន់ និង ទីពីរចេញដីកាបញ្ជូនទៅជំនុំជម្រះ។ រាល់ការចេញនៅដីកាដំណោះស្រាយចៅក្រមស៊ើបសួរត្រូវមានការអោយព័ត៌មានមកកាន់ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវី[58]។

---

52 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១២៧
53 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១២៨
54 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១៣០
55 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១៣៨
56 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១៨៥
57 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៤៧
58 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៤៦ និង២៤៧

**១.២ កិច្ចនីតិវិធីដែលអាចមោឃភាពបាន**

គោលបំណងដែលបង្កើតនៅមានមាត្រា និង បទប្បញ្ញត្តិត្រង់ចំណុចនេះគឺ ច្បាប់មានស្មារតីចង់បានឲ្យមានការស៊ើបសួរដោយ ត្រឹមត្រូវ យុត្តិធម៌ និងមានការទទួលខុសត្រូវនៅសកម្មភាពរបស់ចៅក្រមស៊ើបសួរ ក្នុងការបំពេញកិច្ចរៀងៗខ្លួនឆ្លើយតបទៅសង្គមបច្ចុប្បន្ន។ ដើម្បីឲ្យកាន់តែច្បាប់ និងការសិក្សាស៊ីជំរៅមោឃៈភាពនៃការស៊ើបសួរចែកចេញជា ២ សណ្ឋាន៖ ទីមួយមោឃៈភាពដោយមូលហេតុមិនគោរពតាមទម្រង់ច្បាប់ និង ទីពីរមោឃៈភាពដោយបំពានសិទ្ធិ។

មោឃៈភាពដោយមូលហេតុមិនគោរពតាមទម្រង់ច្បាប់សំដៅ ទៅការអនុវត្តដែលផ្ទុយទៅនិងកិច្ចគតិយុត្តដែលមានចែង។ ហើយកិច្ចគតិយុត្តនេះមានអនុភាពលក្ខណៈដាច់ខាតត្រូវតែគោរព និងបំពេញតាម។ ដូចនេះមោឃៈភាពដោយមូលហេតុមិនគោរពតាមទម្រង់ច្បាប់មាន៥ចំណុចធំៗនៅខាងក្រោម[៥៩]។

**១.២.១ ការបើកស៊ើបសួរ**

ជាស្មារតីច្បាប់កំណត់ដាច់ខាតរាល់បទឧក្រិដ្ឋទាំងអស់ ច្បាប់តម្រូវអោយមានការបើកការស៊ើបសួរជាលក្ខណៈដាច់ខាត បើពុំដូចនេះទេអាចជាមូលហេតុនាំអោយមានការប្តឹងមោឃៈភាព ព្រោះវាជាសកម្មភាពដែលមិនគោរពវិធានច្បាប់[៦០] ។ ប៉ុន្តែករណីពិសេសត្រង់ថា បើបទល្មើសមជ្ឈិមអាចមានការបើកការស៊ើបសួរក៏បាន និង មិនបើកការស៊ើបសួរ អាស្រ័យទៅតាមបទល្មើសមជ្ឈិមធម្មតា និងមជ្ឈិមស្មុកស្មាញ ។ យោងតាមការបកស្រាយខាងលើ កត្តាដែលនាំអោយមានមោឃៈភាពកិច្ចនីតិវិធីមាន២៖

1. មិនមានការបើកស៊ើបសួរចំពោះជនដែលប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ( ឧទាហរណ៍៖ បទឃាតកម្មគិតទុកជាមុន បទទារុណកម្ម និងអំពើឃោរឃៅជាអាទិ៍ )។
2. មិនមានការបើកស៊ើបសួរចំពោះជនដែលប្រព្រឹត្តបទល្មើសមជ្ឈឹម (ឧទាហរណ៍៖ ការជួញដូរ អនីតិជនខុសច្បាប់ បទកាន់កាប់ ឬ ដឹងជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត )។

**១.២.២ សមត្ថកិច្ចដែនដី**

សមត្ថកិច្ចដែនដីសំដៅទៅលើ កិច្ចការដែលចៅក្រមស៊ើបសួរស្ថិតនៅជាមួយសាលាដំបូងរាជធានី-ខេត្តដែលខ្លួនកំពុងបំពេញ (ឧទាហរណ៍៖ ចៅក្រមស៊ើបសួរនៅសាលាដំបូងរាជធានីភ្នំពេញមានសិទ្ធិបំពេញ មុខងារបើកស៊ើបសួររបស់ខ្លួនត្រឹមបទល្មើសដែលកើតនៅទឹកដីរាជធានីភ្នំពេញ មិនអាចធ្វើការបើកការស៊ើបសួរនៅសាលាដំបូងខេត្តបាត់ដំបងតាមអំពើចិត្តដែលខ្លួនចង់នោះទេ)។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងដែនសមត្ថកិច្ចរបស់តុលាការដែលខ្លួនតាំងនៅ ចំពោះគ្រប់បទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចនោះ និងចំពោះ

[៥៩] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥២
[៦០] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១២២

បទល្មើស ដែលកើតឡើងនៅក្រៅសមត្ថកិច្ច ប្រសិនបើជនសង្ស័យម្នាក់ថាបានចូលរួមប្រព្រឹត្តបទល្មើសទាំងអស់ រស់នៅ ឬ ត្រូវបានចាប់ក្នុងដែនសមត្ថកិច្ចរបស់គាត់ ទោះជាត្រូវចាប់មូលហេតុផ្សេងក៏ដោយ ការដោះស្រាយទាក់ទងបណ្តឹងព្រហ្មទណ្ឌដែលមាននោះ អ្នកមានសិទ្ធិមានតែសភាស៊ើបសួរ ប៉ុន្តែករណីមានវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើននោះ អ្នកមានសិទ្ធិសម្រេចមានតែប្រធានតុលាការកំពូល។ យ៉ាងណាមិញ ទោះបីជាវាមិនមែនជាវិធានសមត្ថកិច្ចក្នុងន័យចង្អៀតក៏ដោយ ក៏យើងគួរបន្ថែមថា បើសិនបើការស៊ើបសួរតម្រូវ ចៅក្រមអាចចុះទៅកាន់ទីកន្លែងនៅលើវិសាលភាពដែនដីជាតិទាំងមូលដើម្បីបំពេញ កិច្ចចាំបាច់នានា សម្រាប់ការស៊ើបសួររបស់ខ្លួន បន្ទាប់ពីជូនដំណឹងដល់ព្រះរាជអាជ្ញាអមសាលាដំបូងរបស់ខ្លួន និងព្រះរាជអាជ្ញាអមសាលាដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ។ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួររួមមាន៖

១. ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស

២. ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស

៣. ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

<u>**ចំណាំ**</u>

**ករណីទី១៖** រាល់ទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយសភារួមក្រុមនៃសាលាឧទ្ធរណ៍។ ដីកាសម្រេចលើវិវាទសមត្ថកិច្ចនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា[61]។

**ករណីទី២៖** ចៅក្រមស៊ើបសួរ ( មិនទំនេរ ឈប់សម្រាក មានជម្ងឺ ) ចៅក្រមស៊ើបសួរផ្សេងទៀតនៃ សាលាដំបូងតែមួយ អាចត្រូវចាត់តាំងឲ្យទទួលបន្ទុកបណ្តោះអាសន្នដោយប្រធានសាលាដំបូង ដើម្បីធានាឲ្យបាននូវដំណើរការនៃការស៊ើបសួរ។ ប្រធានសាលាដំបូងចេញដីកាតែងតាំង ដែលបិទផ្លូវតវ៉ាទាំងអស់[62]។

### ១.២.៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរគឺសំដៅចង់ឲ្យចៅក្រមស៊ើសួរ បើកកិច្ចនីតិវិធីស៊ើបសួររបស់ខ្លួនដែលព្រះរាជអាជ្ញាបានសម្រេចចោទប្រកាន់ទៅ។ ប៉ុន្តែអាចមានមូលហេតុជាច្រើននាំអោយកើតមានមោឃភាពចំពោះចំណុចការស៊ើបសួរនេះ៖

---

61 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១២៣

62 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១៣១

១. ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

២. ចៅក្រមស៊ើបសួរអាចស៊ើបសួរបាន[63] ដោយទទួលពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែគ្មានការបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា។

៣ ដីកាសន្និដ្ឋានបញ្ជូនរឿឲ្យស៊ើបសួរមិនភ្ជាប់ជាមួយ និងការចង្អុលបង្ហាញប្រាប់ឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ អត្តសញ្ញាណអោយបានត្រឹមត្រូវជនមានដូចជា៖

1. សេចក្តីសង្ខេបអង្គហេតុ
2. ការកំណត់ឈ្មោះបទល្មើស
3. ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
4. ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើមានអាចកំណត់បាន
5. ចំណាំ ដីការដីកាសន្និដ្ឋានបញ្ជូនរឿឲ្យស៊ើបសួរត្រូវមានកាលបរិច្ឆេទ និង ចុះហត្ថលេខា

### ១.២.៤ វិសាលភាពនៃការប្តឹង

វិសាលភាពនៃបណ្តឹងគឺ សំដៅទៅលើការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាឲ្យចៅក្រមស៊ើបសួរ។ វិសាលភាពនៃការប្តឹងនេះបង្កើតឡើងក្នុងគោលបំណងកម្រិតសិទ្ធិចំពោះចៅក្រមស៊ើប កុំឲ្យមានការបើកស៊ើបសួរតាមតែអំពើចិត្តរបស់ខ្លួន និងពន្លឿនកិច្ចនីតិវិធីស៊ើបសួរអោយបានឆាប់រហ័ស។មូលហេតុនាំអោយកើតមានមោឃភាពកិច្ចនីតិវិធីវិសាលភាពនៃការប្តឹងមាន២ចំណុច៖

១. ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរលើសបទល្មើសដែលមិនមានកំណត់នៅក្នុងដីកាបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿឲ្យស៊ើបសួរ។

២. ចៅក្រមស៊ើបសួរបានរកឃើញលេចចេញនៅបទល្មើសថ្មីហើយតែមិនបាន ផ្តល់ព័ត៍មាននេះមកព្រះរាជអាជ្ញា។

### ១.២.៥ជំនួយរបស់ក្រឡាបញ្ជី

ក្រឡាបញ្ជីមានតួនាទីសំខាន់បំផុតសម្រាប់កិច្ចនីតិវិធីជាមួយ និងចៅក្រមស៊ើបសួរ ព្រោះរាល់ការពិភាក្សាដេញដោលទាក់ទងទៅនឹងការសួរចម្លើយជនត្រូវចោទ និងការស្តាប់ចម្លើយសាក្សី គឺសុទ្ធតែជាភស្តុតាងដល់សំខាន់ចំពោះជនរងគ្រោះ ជនជាប់ចោទ និងស្ថាប័នតុលាការធ្វើការ[64]។ ហើយមិនត្រឹមតែប៉ុណ្ណោះទេ រាល់

[63] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១៣៨ និង១៣៩

[64] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៣២១

កត់ត្រារបស់ក្រឡាបញ្ជីសុទ្ធតែជាភស្តុតាងសំខាន់ដែលតុលាការជាន់ខ្ពស់យកមកពិនិត្យ និងវិនិច្ឆ័យ។ ប៉ុន្តែមូលហេតុនាំអោយកើតមានមោឃភាពនៅចំណុចខាងលើមានដូចជា៖

១ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរមិនមានវត្តមានក្រឡាបញ្ជី

ឧទាហរណ៍៖ រាល់ឯកសារទាំងអស់គ្មានហត្ថលេខាក្រឡាបញ្ជីអមជាមួយ។

២ ក្រឡាបញ្ជីបានបំពេញភារៈកិច្ចចូលក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

ឧទាហរណ៍៖ ដីកាដំណោះស្រាយ ចេញដោយក្រឡាបញ្ជី , កិច្ចនីតិស៊ើបសួរជំនួសធ្វើដោយក្រឡាបញ្ជី។

# ជំពូកទី២

# និតិវិធីនៃការ

# មោឃៈភាព

# ជំពូកទី២

# នីតិវិធីនៃការមោឃៈភាព

នីតិវិធីមោឃៈភាពគឺជា ដំណើរការនីតិវិធីក្នុងការប្តឹងទៅកិច្ចណាមួយដែលធ្វើផ្ទុយទៅនឹងច្បាប់ដែលមានចែងចូលជាធរមាន។ ការប្តឹងនេះទាមទារឲ្យមានការគោរពនៅទម្រង់ច្បាប់ដែលមានចែក និងលក្ខខណ្ឌមួយចំនួន។ ដើម្បីទទួលបានព័ត៌មានលម្អិត និងកាន់តែច្បាស់ស៊ីជម្រៅ ការបង្ហាញមាននៅក្នុងចំណុច ២.១ ស្ថាប័នមានសមត្ថកិច្ច និង២.២ ចំណាត់ការលើបណ្តឹងមោឃៈភាព

## កថាខណ្ឌទី១ ស្ថាប័នមានសមត្ថកិច្ច និងរយៈពេលនៃការប្តឹង

បន្ទាប់ពីបានកើតមាននៅកំហុសឆ្គងណាមួយដោយយថាហេតុ ភាគីនៃបណ្តឹងមានសិទ្ធិអាចធ្វើការលើកឡើងបញ្ហាដែលកើតមាន ប៉ះពាល់ដល់សិទ្ធិ និងបទបញ្ញត្តិច្បាប់ដែលមានចែងចូលជាធរមាន។ នៅក្នុងការដោះស្រាយបញ្ហាខាងលើ យោងតាមស្មារតីនៃច្បាប់ និងមាត្រាដែលមានចែង សមត្ថកិច្ចស្ថាប័នដែលអាចចូលខ្លួនមកដោះស្រាយបាននោះមានតែស្ថាប័នសភាស៊ើបសួរ[65]។ សភាស៊ើបសួរមានតួនាទី យ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាការបំពានបញ្ញត្តិច្បាប់ និងកិច្ចនីតិវិធី។ ជាគោលការណ៍ និងបទបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា សភាស៊ើបសួរមានតួនាទីដោះស្រាយទាំងបញ្ហា ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលស៊ើបសួរ។

**ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌៖** រាល់កិច្ចស៊ើបអង្កេតក្នុងដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌គឺសុទ្ធតែធ្វើឡើងដោយស្ថាប័នអយ្យការត្រួតពិនិត្យ[66] និងសម្របសម្រួល[67]។ ការសម្របសម្រួលដោយស្ថាប័ននេះគឺមានគោលបំណងដើម្បីធានាសិទ្ធិ ក្រមសីលធម៌វិជ្ជាជីវៈ[68] កិច្ចនីតិវិធីនៃច្បាប់[69] និងប្រយោជន៍សាធារណៈ[70]។ យោងទៅតាមការបកស្រាយខាងលើ កិច្ចនីតិវិធីស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ធ្វើសកម្មភាពស្របទៅតាមបញ្ជារបស់ថ្នាក់លើ និងតំរូវការរបស់សង្គម[71]។ ការធ្វើសកម្មភាពនេះគឺត្រូវមានការជូនដំណឹងទៅព្រះរាជអាជ្ញាទៅតាមប្រភេទបទល្មើសដែលមានចែង( បទល្មើសជាក់ស្តែង[72] និងបទល្មើសមិនជាក់ស្តែង[73] )។ ការកើតមាន

65 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៧
66 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៥៩
67 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៧៤
68 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៦៥
69 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១០៩ និង១១៧
70 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា
71 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៧១
72 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៨៩
73 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១១១ ១១៣ ១១៤

នៅកំហុសឆ្គងណាមួយ ដែលនាំឲ្យមានមោឃៈភាពនីតិវិធីនៅក្នុងដំណាក់កាលមន្ត្រីនគលបាលយុត្តិធម៌ កំហុសឆ្គង និង ស្ថាប័នដោះស្រាយនេះមាន២ករណី៖

- ករណីកំហុសឆ្គងផ្នែកវិន័យ សមត្ថកិច្ចដែលដោះស្រាយស្ថាប័នអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[74]។
- ករណីកំហុសកិច្ចនីតិវិធី សមត្ថកិច្ចដែលដោះស្រាយស្ថាប័នសភាស៊ើបសួរ[75]។

**ដំណាក់កាលស៊ើបសួរ៖** ការស៊ើបសួររបស់ចៅក្រមស៊ើបសួរធ្វើឡើងដោយឯករាជ្យ ទន្ទឹមនឹងនោះ កិច្ចនីតិវិធីស៊ើបសួរធ្វើឡើងទាំងដោះបន្ទុក និងដាក់បន្ទុក។ យ៉ាងណាមិញ ការកើតនៅកំហុសឆ្គងណាមួយតែងតែមានចំពោះចំណាត់ការ ទើបនាំឲ្យកើតមានការដាក់ពាក្យបណ្ដឹងសុំមោឃៈភាព។ ការសុំមោឃៈភាពចែកចេញជា២ទម្រង់៖

១/មោឃភាពចំពោះវិធាន

- ការបើកស៊ើបសួរដោយគ្មានការចោទប្រកាន់(RI)[76] ដោយដីការបញ្ជូនរឿងឲ្យស៊ើបសួរ[77]
- ការបើកស៊ើបសួរខុសសមត្ថកិច្ចដែនដី[78]

២/មោឃភាពចំពោះទម្រង់

- ការស៊ើបសួរដោយគ្មាន ជំនួយរបស់ក្រឡាបញ្ជី[79]
- វិសាលភាពនៃបណ្ដឹង[80]

យោងតាមការបកស្រាយខាងលើ ចំពោះចំណាត់ការដែលមានបញ្ហាដែលកើតមានលើការបំពានទម្រង់នឹងវិធានណាមួយស្ថាប័នដែលមានសមត្ថកិច្ចអាចបកស្រាយបានមានតែសភាស៊ើបសួរតែមួយគត់[81] ហើយការដាក់ពាក្យប្ដឹងទៅសភាស៊ើបសួរអាចធ្វើឡើងដោយបុគ្គលពាក់ព័ន្ធដូចជា៖

- ចៅក្រមស៊ើបសួរ
- ព្រះរាជអាជ្ញា
- ជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី

## ២.១ ស្ថាប័នដែលមានសមត្ថកិច្ច

សភាស៊ើបសួរគឺជា សភាពិសេសនៃសាលាឧទ្ធរណ៍ ឬ យើងអាចនិយាយបានម្យ៉ាងទៀតថាជាស្ថាប័នជាន់ខ្ពស់នៃសាលាឧទ្ធរណ៍។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ កិច្ចស៊ើបសួរដែលមានលក្ខណៈជាសេចក្ដីសម្រេច

---

74ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៥៩

75 សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ៖ ចាំង ស៊ីណាត និង រុន ពណ្ណារិទ្ធ ទំព័រ ៤៦

76 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៤៣

77 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៤៤

78 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១២៣

79 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា១២៤

80 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ កថាខណ្ឌទី១ និងទី២ នៃមាត្រា ១២៥

81 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៣

នេះតែងស្តែងឡើងក្រោមរូបភាពសាលដីកាហើយសាលដីកានេះឲ្យឈ្មោះថា សាលដីកាសម្រេច។ ហើយជាគោលការណ៍ ដើម្បីអនុវត្តនូវសិទ្ធិ អំណាចមួយនេះ សភាស៊ើបសួរត្រូវបានគេប្តឹង គឺគាត់មិនមានសិទ្ធិពិនិត្យដោយខ្លួនឯងនោះទេ គឺលុះត្រាតែមាននរណាម្នាក់ប្តឹង។

នៅក្នុងយុត្តាធិការស៊ើបសួរ យើងពិនិត្យឃើញមានមន្ទីរស៊ើបសួរនៅតាមសាលាដំបូងរាជធានី-ខេត្តទាំងអស់ដែលមន្ទីរសភាស៊ើបសួរនេះ នៅពេលធ្វើការបំពេញកិច្ចរបស់ខ្លួនគឺ មានចៅក្រមមួយរូបដែលជាចៅក្រមស៊ើបសួរ។ រីឯចំពោះសភាស៊ើបសួរវិញគឺស្ថិតនៅក្នុងសាលាឧទ្ធរណ៍ នៅពេលដែលបំពេញកិច្ចរបស់ខ្លួន ជាពិសេសនៅពេលជំនុំជម្រះសម្រេចជាសាលដីកាទៅលើប្តឹងតវ៉ានឹងនីតិវិធី និងការសម្រេចរបស់ចៅក្រមស៊ើបសួរគឺត្រូវធ្វើដោយមានចៅក្រមបីរូប។ នៅក្នុងសភាស៊ើបសួរមានរចនាសម្ព័ន្ធរបស់ខ្លួនគឺ ប្រធានមួយរូប និងសមាជិកមួយចំនួនដែលសុទ្ធសឹងតែជាចៅក្រមហើយមានជំនួយការគឺជាក្រឡាបញ្ជី។ សភាស៊ើបសួរបង្កើតឡើងក្នុងគោលបំណង ដើម្បីពិនិត្យនិយ័តភាពនៃនីតិវិធីរបស់ចៅក្រមស៊ើបសួរ ឬ មន្ទីរស៊ើបសួរនៃសាលាដំបូងរាជធានីខេត្ត ទាំងអស់ដើម្បីធ្វើយ៉ាងណាឲ្យការស៊ើបសួរនេះល្អ ត្រឹមត្រូវទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ សភាស៊ើបសួរមានសមត្ថកិច្ចយ៉ាងច្រើនដូចជា ពិនិត្យនិយ័តភាពនូវការស៊ើបសួររបស់ចៅក្រមស៊ើបសួរ[82]ប៉ុន្តែក៏យើងមើលឃើញថាសភាស៊ើបសួរនេះមានចំណុចពិសេសមួយគឺ មានអំណាចឲ្យប្រធានសភាស៊ើបសួរដែលជាអំណាចពិសេសមួយចំនួន [83]។ ការពិនិត្យទៅលើនិយ័តភាពនៃនីតិវិធីមានន័យថា សភាស៊ើបសួរត្រូវពិនិត្យមើលថា តើការប្រព្រឹត្តទៅការបំពេញកិច្ចស៊ើបសួរ ឬ កិច្ចនីតិវិធីផ្សេងៗនោះត្រូវបានបំពេញតាមលក្ខខណ្ឌច្បាប់ដែរឬទេ? និយាយម្យ៉ាងទៀតបានថាកិច្ចនោះ ធ្វើត្រឹមត្រូវតាមច្បាប់ដែរឬទេត្រឹមត្រូវតាមក្រមនីតិវិធីដែរឬ ទេប្រសិនបើមានកិច្ចណាមួយ ដែលមិនត្រឹមត្រូវសភាស៊ើបសួរអាចពិនិត្យលើលទ្ធភាពហើយក្នុងករណីដែលគាត់រកឃើញថាមានកំហុសគាត់អាចសម្រេចធ្វើមោឃៈកម្មបាន។ ហើយមោឃៈកម្មនោះចាត់ទុកកិច្ចនោះជាកិច្ចគ្មានសុពលភាពមិនអាចយកមកប្រើប្រាស់បាននៅក្នុងនីតិវិធី ប៉ុន្តែយើងអាចចោទជាសំណួរបានថា តើសភាស៊ើបសួរនោះគាត់អាចប្រើប្រាស់សិទ្ធិអំណាចនេះនៅក្នុងលក្ខខណ្ឌដូចម្តេច? នៅពេលណាដែលអាចធ្វើបានជាគោលការណ៍នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌសភាស៊ើបសួរ មិនអាចទទួលទទួលសំណុំរឿងយកពិនិត្យដោយយកមកដោះស្រាយដោយខ្លួនឯងនោះទេ ទាមទារត្រូវតែមានអ្នកប្តឹង។ តើគាត់អាចអនុវត្តអំណាចនៅក្នុងការត្រួតពិនិត្យនិយ័តភាពនៃកិច្ចនីតិវិធីនេះនៅក្នុងក្របខណ្ឌនៃការប្តឹងយ៉ាងដូចម្តេច? ដូច្នេះយើងបំបែកបណ្តឹងចេញជាពីរ៖[84]

---

82 សៀវភៅមេរៀនស្តីអំពី សភាស៊ើបសួរ ទំព័រ២ ដោយ៖ ស៊ាង សំភស់

83 ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ថ្ងៃទី 16 ខែកក្កដា ឆ្នាំ២០១៤ មាត្រា ៣៧

84 សៀវភៅលោក ស៊ាងសំភស់ ចំណងជើង៖ សភាស៊ើបសួរ

ក/ បណ្តឹងសុំមោឃៈភាពបានន័យថា គឺជាបណ្តឹងដែលគោលបំណងតែម្តងថា សុំមោឃៈភាពកិច្ចណាមួយ។ ដែលបណ្តឹងនេះអាចធ្វើឡើងដោយចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលគាត់ពិនិត្យឃើញថាកិច្ចនោះមានភាពមិនប្រក្រតី កិច្ចនោះអនុវត្តខុសក្រមនីតិវិធីព្រហ្មទណ្ឌកិច្ចនោះធ្វើឲ្យប៉ះពាល់ដល់ សិទ្ធិការពារខ្លួនរបស់គាត់កិច្ចនោះធ្វើឲ្យប៉ះពាល់ដល់អ្វី ដែលច្បាប់ចែងថា ប្រសិនបើជាធ្វើខុសនឹងត្រូវមោឃៈភាព។ និយាយជារួមភាគីដែលពិនិត្យឃើញថាមានបញ្ហាមានកំហុសនៅលើកិច្ចនីតិវិធីគាត់អាចលើកករណីប្តឹងទៅសភាស៊ើបសួរបាន។ កិច្ចទាំងនេះអាចជា កិច្ចដែលបំពេញនៅក្នុងដំណាក់កាលស៊ើបអង្កេត កិច្ចដែលបំពេញនៅក្នុងដំណាក់កាលស៊ើបសួរ ក៏រួមបញ្ចូលទាំងកិច្ចចោទប្រកាន់។

ឧទាហរណ៍៖ គេអាចប្រឆាំងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលជាកិច្ចចោទប្រកាន់មួយ។

ខ/ ដើម្បីធ្វើការពិនិត្យលើនិយ័តភាពនៃកិច្ចនីតិវិធីនេះបាន ប៉ុន្តែមិនមែននៅក្នុងក្របខ័ណ្ឌនៃបណ្តឹងសុំមោឃៈភាពនោះទេ ប៉ុន្តែស្ថានភាពនេះគឺជាបណ្តឹងដទៃផ្សេងទៀតដែលអនុញ្ញាតឲ្យសភាស៊ើបសួរមានសមត្ថកិច្ច យកសំណុំរឿងនីតិវិធីមកធ្វើការពិនិត្យ។

ឧទាហរណ៍៖ ការប្តឹងពាក់ព័ន្ធអំពីដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

ករណីខាងលើសភាស៊ើបសួរ ទទួលសំណុំរឿងមកពិនិត្យនៅពេលដែលគាត់ឃើញថាមានកំហុសនីតិវិធីដែលត្រូវធ្វើមោឃៈភាព ដែលសភាស៊ើបសួរអាចផ្ទៀងផ្ទាត់ទៅនឹងមាត្រា ២៦១ ដែលមានចែងថា រាល់ពេលដែលទទួលបានបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនិយ័តភាពនៃនីតិវិធីនិងការប្រព្រឹត្តទៅដល់ល្អនៃនីតិវិធី។ កាលណាពិនិត្យឃើញមូលហេតុនៃមោឃៈភាពសភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯង នៅកិច្ចនីតិវិធីទាំងមូល ឬ ដោយផ្នែកណាមួយ។ សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងនៅក្នុងមេត្រា ២៨០ (អនុលោមនៃមោឃកម្ម) នៃក្រមនេះ។ នេះគឺជាក្របខ័ណ្ឌដែលថា សភាស៊ើបសួរអាចមានសមត្ថកិច្ចក្នុងការពិនិត្យអំពីនិយ័តភាព ប៉ុន្តែបើពិនិត្យមើលលក្ខខណ្ឌមួយទៀតគឺ ទាក់ទងជាមួយនឹងដំណាក់កាល តើដំណាក់កាលនៅក្នុងវិធីណាខ្លះដែលគេអាចស្នើសុំឲ្យសភាស៊ើបសួរសម្រេចមោឃៈភាព? ចំណុចនេះ ការពិនិត្យមើលនៅក្នុងមាត្រា ២៥១(ការលុបលាងមោឃៈភាពដោយដីកាដំណោះស្រាយ) ដែលបានចែងថា ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃៈភាពនៃនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃៈភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។ ក្នុងឃ្លានេះមានន័យថា ការស្នើសុំមោឃៈភាពនៃកិច្ចនីតិវិធីណាមួយត្រូវធ្វើ ឲ្យបានមុនការបិទការស៊ើបសួរដែលចូលជាស្ថាពរ។ ម្យ៉ាងទៀតការស្នើសុំមិនអាចសុំមោឃៈភាពនៃកិច្ចនីតិវិធីនោះបានទេ នៅចំពោះមុខតុលាការជំនុំជម្រះ។ ដូច្នេះការណាឆ្លងកាត់ចូលក្នុងដំណាក់កាលជំនុំជម្រះគឺ លែងអាចសុំមោឃៈភាពនៃនីតិវិធីបានទៀតឡើយដែលនេះគឺជាត្រូវធ្វើឡើងដោយបន្សល់ទុកនូវនីតិវិធី[៨៥]។

[៨៥] ប្រសាសន៍បកស្រាយរបស់ឯឧត្តម ផូវ សំភី ឯឧត្តម កើត រិទ្ធ និងឯឧត្តម ប៊ិន ហុន

### ២.១.១ រយៈពេលនៃការប្តឹង

យ៉ាងណាមិញ រយៈពេលនៃការដាក់ពាក្យបណ្តឹងសុំមោឃៈភាពក្នុងនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិច្បាប់ដែលមានចែង មានភាពស្រពិចស្រពិលធ្វើឲ្យមិនមានការកំណត់នៅរយៈពេលណាមួយអោយពិតប្រាកដ និងជាក់លាក់នោះទេ ពោលគឺទាមទារអោយមានការពិចារណារួមផ្សំទាំងការបកស្រាយទៅតាមស្ថានភាពនៃការអនុវត្តជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយ រយៈពេលក្នុងការមោឃៈភាពមិនមានការកំណត់អោយបានច្បាស់ ប៉ុន្តែការចង្អុលបង្ហាញទាក់ទងនឹងបញ្ហានេះមានបង្កើបក្នុង មាត្រា២៥៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងករណីដែលមានការប្តឹងមោឃៈភាព រយៈពេលនៃការប្តឹងអាចធ្វើបានគ្រាប់ពេលឲ្យតែការលើកឡើងនោះធ្វើ នៅមុនពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ។ ទន្ទឹមនឹងនេះ ប្រសិនបើមានការលើកឡើងនៅមោឃៈភាពនៅចំពោះមុខតុលាការក្នុងពេលដែលឈានដល់ ដំណាក់កាលជំនុំជម្រះក្តី ការលើកឡើងនេះចាត់ទុកថា គ្មានមោឃៈភាព[86]។

### ២.១.២ ចំណាត់ការលើបណ្តឹងមោឃៈភាព

បន្ទាប់ពីការទទួលបានពាក្យបណ្តឹង ឯកសារពាក់ពន្ធ័ ការពិនិត្យមើលនិយ័តភាពនៃកិច្ចនីតិវិធីរួមទាំងការប្រព្រឹត្តិទៅ និងកិច្ចនីតិវិធីពិភាក្សាដេញដោលរួចមក[87]។ បន្ទាប់ពីបានពិនិត្យឃើញមូលហេតុមោឃៈភាពដោយពាក្យបណ្តឹងសុំមោឃៈកម្មចំពោះកិច្ចនីតិវិធី ឬ លិខិតណាមួយនៃនីតិវិធី។ ក្នុងករណីនេះ ប្រធានសភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬ ដោយផ្នែកណាមួយ[88]។ ទន្ទឹមនឹងនេះ កិច្ច ឬលិខិតដែលចាត់ទុកជាមោឃៈត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ[89]។

### ២.២ ការដាក់ពាក្យបណ្តឹង

នៅក្នុងដំណាក់កាលនៃការស្នើរសុំដាក់ពាក្យបណ្តឹងសុំមោឃៈភាពនៅក្នុង កិច្ចនីតិវិធីចៅក្រមស៊ើបសួរ ឬ កិច្ចនីតិវិធីមន្រ្តីនគរបាលយុត្តិធម៌ ការដាក់ពាក្យនោះត្រូវធ្វើឡើងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរសាលាឧទ្ធរណ៍។ បន្ទាប់ពីការទទួលដំណឹងនៃពាក្យបណ្តឹងរួចហើយ ក្រឡាបញ្ជីនៃសភាស៊ើបសួរត្រូវតែឲ្យដំណឹងភ្លាមទៅ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬ មេធាវី[90]។ បន្ទាប់មកទៀត ក្រឡាបញ្ជីនៃសភាស៊ើបសួរនឹងធ្វើការសុំឲ្យក្រឡាបញ្ជីចៅក្រមស៊ើបសួរ ក្រឡាបញ្ជីព្រះរាជអាជ្ញា ឬ មេធាវី ផ្ញើមកឲ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬ សំណុំរឿងបង្ការទុក[91]។ ការដាក់ពាក្យបណ្តឹងអាចធ្វើបានតាម៣ទម្រង់[92]៖

---

86 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៦
87 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៦១
88 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៨០
89 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៨០ កថាខណ្ឌទី២
90 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៧ វគ្គព្យាខណ្ឌទី១
91 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៧ វគ្គព្យាខណ្ឌទី២
92 ប្រសាសន៍បកស្រាយរបស់ឯឧត្តម ផូវ សំភី ឯឧត្តម កើត រិទ្ធ និងឯឧត្តម ប៊ិន ហុន

- ការដាក់ពាក្យបណ្តឹងទៅមន្ទីរក្រឡាបញ្ជីសាលាដំបូង
- ការដាក់ពាក្យបណ្តឹងទៅមន្ទីរក្រឡាបញ្ជីសភាស៊ើបសួរ
- ការដាក់ពាក្យបណ្តឹងនៅចំពោះមុខប្រធានមណ្ឌលឃុំខ្លួន ឬ ប្រធានពន្ធនាគារ

### ២.២.១ ការពិនិត្យ និងទទួលបណ្តឹង

ចំពោះការពិនិត្យនៃពាក្យបណ្តឹងត្រូវធ្វើឡើងដោយប្រធានសភាស៊ើបសួរ និងមានការពិនិត្យដោយម៉ត់ចត់រួមទាំងការផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបានឬទេ។ បន្ទាប់ពីបានទទួលបាននូវពាក្យបណ្តឹង ឯកសារពាក់ព័ន្ធ និងការពិនិត្យចប់សព្វគ្រប់ហើយ ប្រធានសភាស៊ើបសួរនឹងធ្វើការជូនដំណឹងដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនៃការបើកសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់គូភាគី និង ដល់មេធាវី[93]។ ការជូនដំណឹងចែកចេញជា២គឺ[94]៖

១/ ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើឡើងដូចតទៅ៖

- ដោយផ្ទាល់មាត់
- តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន

២/ ការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី៖

- ដោយផ្ទាល់មាត់
- តាមផ្លូវរដ្ឋបាល
- តាមរយៈអគ្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

### ២.២.២ ការពិភាក្សាដេញដោល និងការសម្រេចសេចក្តី

ការពិភាក្សាដេញដោលគឺសំដៅទៅលើសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីស្វែងរកនៅសេចក្តីសម្រេចដ៏ត្រឹមត្រូវសម្រាប់ភាគីដែលដាក់ពាក្យប្តឹង រីឯការសម្រេចសេចក្តីសំដៅទៅលើសកម្មភាពដែលតុលាការទទួលបានការអះអាងពីភាគី និងអង្គហេតុដើម្បីធ្វើជាមូលដ្ឋានឈានទៅរកការចេញសាលដីកា។ ប៉ុន្តែសកម្មភាពដេញដោល និងការសម្រេចមាននីតិវិធីយ៉ាងណា សូមចុះទៅពិនិត្យនៅចំនុចដូចខាងក្រោម៖

#### ក/ ដំណាក់កាលពិភាក្សាដេញដោល

ក្រោយពីបានទទួលពាក្យបណ្តឹង និងការពិនិត្យចប់សព្វគ្រប់ហើយ ដំណើរការបន្តឈានដល់ការពិភាក្សាដេញដោល។ ដំណើរការនៃការពិភាក្សាដេញដោល ត្រូវប្រព្រឹត្តទៅនៅក្នុងបន្ទប់ពិភាក្សាដេញនៃសាលាឧទ្ធរណ៍។ បុគ្គលដែលពាក់ព័ន្ធទៅនឹងពាក្យបណ្តឹងត្រូវបង្ហាញខ្លួនតាមការកំណត់ថ្ងៃបើកសវនាការ ដោយការ

---

[93] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៨ វគ្គព្យាខណ្ឌទី១

[94] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៧ វគ្គព្យាខណ្ឌទី២

ជូនដំណឹង[95]។ ទន្ទឹមនឹងនេះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីមានសិទ្ធិពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ ហើយគូភាគីត្រូវត្រៀមប្រគល់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត១ថ្ងៃមុនពេលបើកសវនាការ។ ក្រោយពីទទួលបាននូវដំណឹងគូរភាគីត្រូវត្រៀមសារណា និងសេចក្តីសន្និដ្ឋានធ្វើការសង្ខេបជូនប្រធានសវនាការ។ សភាស៊ើបសួរអាចបង្គាប់អោយគូភាគីព្រមទាំងជនត្រូវចោទជាប់ឃុំ ចូលមកបង្ហាញខ្លួនដោយផ្ទាល់ហើយនិងផ្តល់ភស្តុតាងដោយមូលហេតុនៃការប្តឹង។

**ខ/ ដំណាក់កាលសម្រេចសេចក្តី**

បន្ទាប់ពីបានធ្វើការពិភាក្សាដេញដោលបានបញ្ចប់ ប្រធានសវនាការចូលធ្វើការពិគ្រោះសម្រេច ដោយគ្មានវត្តមានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគី និងមេធាវីឡើយ។ សាលដីកាប្រកាសនៅពេលសវនាការជាអសាធារណៈនៅថ្ងៃនោះ ឬ ក៏នៅពេលសវនាកាក្រោយក៏បានដែរ។ ប៉ុន្តែសាលដីកាត្រូវតែមានសំអាងហេតុ និងត្រូវតែមានធាតុដែលចាំបាច់ដល់ការត្រួតពិនិត្យរបស់តុលាការកំពូល។ សាលដីកាត្រូវមានចុះហត្ថលេខាដោយប្រធានសភាស៊ើបសួរ។ សាលដីកាការត្រូវជូនដំណឹងដោយផ្ទាល់មាត់ក្នុងរយៈពេលខ្លីបំផុតដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងក្រឡាបញ្ជីត្រូវចុះទិន្នន័យអំពីកាលបរិច្ឆេទនៃការជូនដំណឹង។

[95] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៥៨

# ជំពូកទី៣

# អានុភាពនៃការ

# មោឃៈភាពនីតិវិធី

# ជំពូកទី៣

# អានុភាពនៃការមោឃភាពនីតិវិធី

ការកំណត់អំពីមោឃៈភាពនៅក្នុងកិច្ចនីតិវិធីព្រហ្មទណ្ឌ គឺបង្ហាញឲ្យឃើញពីបញ្ញត្តិដែលការពារដល់ប្រយោជន៍របស់ជនល្មើស ដែលអាជ្ញាធរមានសមត្ថកិច្ចត្រូវតែគោរពជាដាច់ខាត។ មោឃៈភាពនៃកិច្ចនីតិវិធីនាំឲ្យនីតិវិធីនោះលែងមានសុពលភាពព្រោះខុសនឹងទម្រង់ច្បាប់។ នៅពេលដែលនីតិវិធីមួយត្រូវបានមោឃៈភាពនោះនឹងនាំឲ្យកិច្ចនីតិវិធីនោះមិនអាចទទួលយកបាន ហើយនឹងអាចនាំឲ្យអនុវត្តសារជាថ្មីក៏ថាបាន។ ករណីខ្លះមោឃៈភាពនីតិវិធីនឹងអាចក្លាយជាមូលហេតុដែលនាំតម្កល់ទុករឿងឥតចាត់ការ ឬ លើកលែងការចោទប្រកាន់ក៏អាចមានផងដែរ។ ដោយសារតែមោឃៈភាពនៃកិច្ចនីតិវិធីកើតមានឡើងតែនៅក្នុងដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរនោះអនុភាពនៃមោឃៈភាពនឹងធ្វើការលើកឡើងតែនៅក្នុងពីរដំណាក់កាលនេះប៉ុណ្ណោះ។

## កថាខណ្ឌទី១ ដំណាក់កាលស៊ើបអង្កេត

ក្នុងករណីមោឃៈភាពបានកើតឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត ចំពោះអនុភាព គឺពុំត្រូវបានកំណត់ច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនោះឡើយ។ មូលហេតុនៃមោឃៈភាពដូចមានចែងនៅក្នុងមាត្រា ១០៩ និងមាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ គឺជាមូលហេតុដែលកើតចេញពីការអនុវត្តនីតិវិធីមិនត្រូវត្រូវតាមទម្រង់ដែលច្បាប់កំណត់របស់មន្ត្រីនគរបាលយុត្តិធម៌។ ជាគោលការណ៍ ករណីដែលទម្រង់នៃកិច្ចនីតិវិធីណាមួយត្រូវបានមោឃភាពនោះមានន័យថាកិច្ចនោះពុំមានសុពលភាពអាចទទួលស្គាល់បាននោះទេ (៣.១.១) ប៉ុន្តែបញ្ហាត្រង់ថាតើកិច្ចនោះនឹងត្រូវអនុវត្តធ្វើសាជាថ្មី ឬ មួយយ៉ាងណា(៣.១.២)។

### ៣.១ ការបញ្ចប់សុពលភាពនៃកិច្ចស៊ើបអង្កេត

ភាពមិនច្បាស់លាស់នៃមូលដ្ឋានគតិយុត្តស្តីពីអនុភាពនៃមោឃៈភាពនៃការមិនគោរពវិធានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃដំណាក់កាលស៊ើបអង្កេត គឺជាវិញ្ញាសារដើម្បីស្វែងរកការបកស្រាយមួយឲ្យបានពេញលេញទៅលើបញ្ហានេះ។ ក្នុងទម្រង់នីតិវិធីនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌អនុវត្តការងាររបស់ខ្លួនគឺត្រូវមានកំណត់ហេតុជានិច្ច ដើម្បីកសាងសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញា ក្នុងការពិនិត្យ និងសម្រេចលើការចោទប្រកាន់ ឬ មិនចោទប្រកាន់។ ប្រសិនបើ កិច្ចណាមួយត្រូវបានសម្រេចថាមោឃៈភាពនោះ មានន័យថាកិច្ចនោះគឺគ្មានលទ្ធផលនៃសកម្មភាពដែលបានអនុវត្តនោះទេ ហើយត្រូវដកចេញពីសំណុំរឿង។ ប៉ុន្តែការបញ្ចប់កិច្ចណាមួយនៃដំណើរការស៊ើបអង្កេតមិនមែនមានន័យថា បញ្ឈប់ ឬ ប៉ះពាល់ដល់សុពលភាពនៃកិច្ចស៊ើបអង្កេតទាំងស្រុងនោះទេ មានន័យថា ការអនុវត្តនីតិវិធីនៅតែអាចបន្តទៅមុខទៀត។ បើទោះបីជាយ៉ាងនេះ មន្ត្រីនគរបាលយុត្តិធម៌អាចនឹងមានភាពលំបាកក្នុងការអនុវត្តការងារស៊ើបអង្កេតបន្តទៀត។ ឧទាហរណ៍៖ ករណីដែលការឆែកឆេរធ្វើឡើងដោយខុសនីតិវិធីពេលវេលា ពេលនោះម្ចាស់ទីតាំងអាចប្តឹងពីបទរំលោភលើលំនៅឋាន

ស្ថានទម្ងន់ទាក់ទងនឹងចារី តាមមាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។ ដូច្នេះ ត្រង់ចំណុចនេះ ប្រសិនបើកិច្ចនីតិវិធីត្រូវបានសម្រេចមោឃៈភាពដោយសភាស៊ើបសួរនោះ កិច្ចនីតិវិធីដែលបានអនុវត្តហើយត្រូវមោឃៈភាពនោះគឺ មិនអាចយកប្រើប្រាស់នៅក្នុងសំណុំរឿងបាននោះទេ។ ក្នុងស្ថានភាពនេះ មានករណីមួយនឹងកើតឡើង គឺថានៅពេលដែលសភាស៊ើបសួរកំពុងពិនិត្យ និងសម្រេចលើបណ្តឹងសុំមោឃៈភាព នោះតើដំណើរការស៊ើបអង្កេតនៅពេលនោះត្រូវបានបន្តអនុវត្ត ឬ ផ្អាកជាបណ្តោះអាសន្ន។ ករណីនេះបើក្នុងដំណាក់កាលស៊ើបសួរ គឺចៅក្រមស៊ើបសួរអាចបន្តការអនុវត្តកិច្ចរបស់ខ្លួនបាន[96]។ ប៉ុន្តែចំណុចនេះពុំបានចែងឡើយនៅក្នុងការស៊ើបអង្កេត នេះគឺជាបញ្ហាផ្នែកគតិយុត្តមួយដែលត្រូវទាមទារឲ្យមានការបកស្រាយ។ ជាគោលការណ៍ការស៊ើបអង្កេតមានកំណត់ពេលវេលា ជាក់ស្តែងការស៊ើបអង្កេតករណីជាក់ស្តែងគឺមានពេលវេលា ត្រឹមតែ០៧ថ្ងៃប៉ុណ្ណោះ[97] ដូច្នេះប្រសិនបើរយៈពេលនេះត្រូវបានបញ្ឈប់ ឬ ផ្អាកនោះនឹងប៉ះពាល់ដល់ប្រសិទ្ធភាពទាំងមូលនៃការងារស៊ើបអង្កេត នោះមានន័យថា ការសម្រេចមោឃៈភាពលើកិច្ចនីតិវិធីណាមួយនឹងមិននាំមានការផ្អាក ឬ បញ្ឈប់កិច្ចស៊ើបអង្កេតផ្សេងទៀតនោះទេ។ បើទោះបីជាដូច្នោះ ការបកស្រាយបែបនេះនឹងមិនគួរយកមកឡើយចំពោះការស៊ើបអង្កេតបឋម ព្រោះការស៊ើបអង្កេតប្រភេទនេះពុំបានកំណត់រយៈពេលច្បាស់លាស់នោះទេ។

### ៣.១.១ អនុវត្តកិច្ចនៃនីតិវិធីសាជាថ្មី

មូលដ្ឋានគតិយុត្តិ នៅតែជាបញ្ហាក្នុងការបកស្រាយលើចំណុចនេះ។ ជាគោលការណ៍នៅពេលដែលកិច្ចនៃការស៊ើបអង្កេតណាមួយត្រូវបានសម្រេចមោឃៈភាពដោយសភាស៊ើបសួរ បន្ទាប់ពីមានបណ្តឹងសុំមោឃៈភាពនោះកំណត់ហេតុ ឬ លទ្ធផលនៃការស៊ើបអង្កេតនោះត្រូវបានចាត់ទុកជាអាសាបង់ឥតបានការ និងត្រូវដកហូតចេញពីសំណុំរឿង។ បញ្ហាត្រង់ថាប្រសិនបើកិច្ចស៊ើបអង្កេតនោះទើបតែបានចាប់ផ្តើមអនុវត្តមិនទាន់ចេញជាលទ្ធផលនោះឡើយទេ តែដោយសារតែអនុវត្តខុសវិធានបញ្ញត្តិទើបត្រូវបានសម្រេចមោឃៈភាព តើករណីនេះការស៊ើបអង្កេតសារជាថ្មីអាចត្រូវបានធ្វើឡើងដែរឬទេ?

ករណីនេះ ការបើកការស៊ើបអង្កេតសាជាថ្មី ឬ អត់គឺអាស្រ័យលើថាតើកិច្ចនៃការស៊ើបអង្កេតមួយនោះសំខាន់កម្រិតណាក្នុងការកសាងសំណុំរឿង។ ម្យ៉ាងទៀត គឺអាស្រ័យលើថាតើរយៈពេលសម្រាប់ការស៊ើបអង្កេតនោះនៅសល់ប៉ុន្មានដែរ? មូលដ្ឋានទាំងនេះអាចជាទស្សនៈ ដែលបង្ហាញឲ្យឃើញពីវិធីសាស្រ្តនៃការសម្រេចសេចក្តីរបស់សភាស៊ើបសួរ ដោយហេតុថាមានតែសភាស៊ើបសួរមួយប៉ុណ្ណោះដែលសម្រេចលើបញ្ហាមោឃៈភាព ដូច្នេះការសម្រេចឲ្យបញ្ឈប់ការស៊ើបអង្កេត ឬ ស៊ើបអង្កេតសារជាថ្មី គឺជាសមត្ថកិច្ចរបស់ស្ថាប័នមួយនេះ។ បើយោងតាមមាត្រា ២៨០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ គ្រាន់តែចែងថា "កិច្ច ឬ

[96] មាត្រា ២៥៥ នៃក្រមនីតីវិធីព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ២០០៧

[97] មាត្រា ១០៦ នៃក្រមនីតីវិធីព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ២០០៧

លិខិតដែលត្រូវបានចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ" ប៉ុណ្ណោះ។

**៣.១.២ ដំណាក់កាលស៊ើបសួរ**

កាលណាបានទទួលបណ្ដឹងសុំមោឃៈកម្មចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យប្ដឹងសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃៈកម្មនេះត្រូវធ្វើទៅលើកិច្ច ឬ លិខិតផ្សេងទៀតដែរឬទេ។ កិច្ច ឬ លិខិតដែលត្រូវបានចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ[១៩]។

ក្រោយពីធ្វើមោឃៈកម្មរួចសភាស៊ើបសួរអាច បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ (៣.២.១) ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត(៣.២.២) ឬ បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ (៣.២.៣)។

**៣.២ បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ**

ជាវិបាកនៃមោឃៈកម្ម ការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ គឺធ្វើឡើងបន្ទាប់ពីសភាស៊ើបសួរសម្រេចថាកិច្ច ឬ លិខិតណាមួយនៃនីតិវិធីត្រូវបានមោឃៈភាព។ ចំពោះការបង្វិលទៅចៅក្រមស៊ើបសួរវិញនេះមានអនុភាពនាំឲ្យចៅក្រមស៊ើបសួរ អាចស៊ើបសួរសារឡើងវិញ ឬ ក៏បន្តការស៊ើបសួររបស់ខ្លួនជាបន្តទៅទៀត។ ករណីនេះមិនមានន័យដាច់ខាតថា នៅពេលដែលមាន បណ្ដឹងមោឃៈកម្មកិច្ចស៊ើបសួរត្រូវបានផ្អាកនោះ ព្រោះបើអនុលោមតាមមាត្រា ២៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានកំណត់អំពីភាពមិនដាច់ខាតនៃ បណ្ដឹងមោឃៈកម្មលើដំណើរការនៃការស៊ើបសួរ មានន័យថា បើទោះបីជាមានពាក្យសុំប្ដឹងមោឃកម្មក៏ដោយ ក៏ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបានលើកលែងតែមានសេចក្ដីសម្រេចផ្ទុយពីនេះរបស់ប្រធានស៊ើបសួរ។

**៣.២.១ ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត**

ករណីនេះស្ដែងឲ្យឃើញពីកំហុសរបស់ចៅក្រមស៊ើបសួរ ដែលមិនអាចឲ្យគាត់បន្តលើការងារស៊ើបសួរនៃសំណុំរឿងនោះទៀតបានទេ។ ខុសពីករណីទីមួយបើទោះបីជាសម្រេចមោឃៈកម្មហើយក៏ដោយ ក៏សភាស៊ើបសួរនៅមានទំនុកចិត្តដើម្បីឲ្យចៅក្រមស៊ើបសួរដដែលទទួលស៊ើបសួរលើសំណុំរឿងនោះដដែល។ ប៉ុន្តែករណីទី ២ នេះទំនុកចិត្តលើការអនុវត្តការងាររបស់ចៅក្រមស៊ើបសួរពុំត្រូវបានផ្ដល់ឲ្យទៀតឡើយ មូលហេតុអាចស្ដែងចេញពីការអនុវត្តការងាររបស់ចៅក្រមស៊ើបសួរមានកំហុសធ្ងន់ធ្ងរ និងមិនគួរអនុវត្តកិច្ចនីតិវិធីនេះបន្តទៅទៀតបាន។ ដូច្នេះហើយការសម្រេចដកហូតសមត្ថកិច្ចនឹងបញ្ជូនសំណុះរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត គឺ

[១៩] មាត្រា ២៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

សមស្រេប និងឆ្លើយតបទៅនឹងមូលហេតុដែលនាំឲ្យមោឃៈកម្មដែលចោទឡើង។ អំណាចនៅក្នុងការកែសម្រួល នឹងបំពេញបន្ថែមនៅក្នុងនីតិវិធីនៅពេលដែលសភាស៊ើបសួរទទួលបណ្ដឹង។ សភាស៊ើបសួរអាចបង្គាប់ឲ្យធ្វើកិច្ច ស៊ើបសួរបន្ថែមដូចដែលមានចែងនៅក្នុងមាត្រា ២៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីនេះសភាស៊ើបសួរ អាចចាត់តាំងសមាជិកណាម្នាក់របស់ខ្លួនឲ្យធ្វើការស៊ើបសួរ ដែលត្រូវកំណត់ថា តើត្រូវធ្វើអ្វីខ្លះ ឬអាចស្នើសុំទៅ ចៅក្រមស៊ើបសួរណាមួយ អោយធ្វើការកិច្ចនោះជំនួស។ សភាស៊ើបសួរអាចពន្លាតការចោទប្រកាន់ទៅលើបទ ល្មើសផ្សេងទៀត[99]។ នៅក្នុងសំណុំរឿងនេះនីតិវិធីនេះប្រសិនបើមានអង្គហេតុតែពាក់ព័ន្ធទៅនឹងបទល្មើសដទៃ ទៀត ឬ ពន្លាតការចោទប្រកាន់ទៅលើបុគ្គលផ្សេងទៀត ដែលច្បាប់បានហៅថា ការដាក់ឲ្យស្ថិតនៅក្រោមការ ពិនិត្យចំពោះបុគ្គលពាក់ព័ន្ធផ្សេងទៀត[100]។ ម្យ៉ាងទៀតគាត់អាចធ្វើការវាយតម្លៃក្នុងការកំណត់បទល្មើសនោះ ឡើងវិញផងដែរ។ អំណាចនៅក្នុងការកែសម្រួល និងបំពេញបន្ថែមនៅក្នុងនីតិវិធីគឺ អនុវត្តនៅពេលដែលសភា ស៊ើបសួរទទួលបានបណ្ដឹងទាំងមូល[101]។

### ៣.២.២ បន្តការស៊ើបសួរដោយខ្លួនឯង

ក្នុងករណីនេះ គឺសភាស៊ើបសួរសម្រេចយកសំណុំរឿងនោះមកបន្តការស៊ើបសួរដោយខ្លួនឯងវិញម្ដង ពោលគឺមិនបញ្ជូនទៅចៅក្រមស៊ើបសួរដដែលវិញ ឬមួយក៏ដកហូតចៅក្រមស៊ើបសួរហើយបញ្ជូនទៅចៅក្រម ស៊ើបសួរផ្សេងទៀតនោះទេ។

អំណាចបន្តការស៊ើបសួរ ចំណុចនេះធ្វើឲ្យសភាស៊ើបសួរក្លាយទៅជាយុត្តាធិការស៊ើបសួរយ៉ាងពិតប្រាកដ បាន ដែលបំពេញកិច្ចតាមផ្ទាល់តែម្ដង។

ការសម្រេចដកសំណុំរឿងបែបនេះ សភាស៊ើបសួរត្រូវតែពិនិត្យនិងមើលពីកំហុសបើមិនដូច្នេះទេ សភាស៊ើបសួរមិនអាចដកបានឡើយក្នុងករណីបំពេញកិច្ចស៊ើបសួរនេះសភាស៊ើបសួរអាចប្រើប្រាស់សិទ្ធិ អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ[102]។

កាលណាសភាស៊ើបសួរសម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯងនោះសភាស៊ើបសួរប្រគល់ ភារកិច្ចទៅ សមាជិករបស់ខ្លួនម្នាក់ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែអំណាច ដែលមានចែងនៅក្នុង ជំពូកទី ៥ ស្ដីពីការបិទការស៊ើបសួរនៃមាតិកាទី ១ ស្ដីពីចៅក្រមស៊ើបសួរ ក្នុង គន្លឹះនេះ។ កាលណាការស៊ើបសួរ ហាក់ដូចជាត្រូវបញ្ចប់ សំណុំរឿងនាំនីតិវិធីត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធាន នៃសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាកាសសភាស៊ើបសួរបិទការស៊ើបសួរ តាមសាលដីកាដំណោះ

99 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៦៣

100 ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៦៤

101 ប្រសាសន៍បកស្រាយរបស់ឯឧត្តម ផូវ សំភី ឯឧត្តម កើត រិទ្ធ និងឯឧត្តម ប៊ុន ហុន

102 ប្រសាសន៍បកស្រាយរបស់ឯឧត្តម ផូវ សំភី ឯឧត្តម កើត រិទ្ធ និងឯឧត្តម ប៊ុន ហុន

ស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅ ជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់។ ប្រសិនបើយល់ឃើញ ថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរ សម្រេច បញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។ ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅៈ

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់។
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។
- បណ្តឹងអាជ្ញារលត់

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់ កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះ ចំពោះអំពើមួយចំនួននឹងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត។

ក្នុងករណីដែលសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំសេចក្តីសម្រេចនោះត្រូវមានអនុភាពអនុវត្តភ្លាម ដោយមិនរងចាំផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាឡើយ[103]។

[103] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា២៨២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវកន្លងមក និងតាមរយៈការបកស្រាយយ៉ាងហូរហែរពីប្រធានបទ " **មោឃៈភាពក្នុងនីតិវិធីព្រហ្មទណ្ឌ** " យើងបានដឹងហើយថា មោឃៈភាពនីតិវិធីត្រូវបានផ្សាភ្ជាប់គ្នារវាងច្បាប់ជាច្រើនបូករួមទាំង ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ ដូចជា៖ ក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ ជាដើម។ ទន្ទឹមនឹងនេះ ឈានមកដល់ចំណុចជាចុងក្រោយនេះបានសបង្ហាញយ៉ាងច្បាស់អោយឃើញថា មោឃៈភាពគឺជាទណ្ឌកម្មមួយដែលដាក់ចំពោះការអនុវត្តមិនគោរពវិធានច្បាប់ និងលក្ខខណ្ឌច្បាប់ដែរមានចែង ហើយស្ថានភាពមិនគោរពច្បាស់នោះ ចាត់ទុកថា មោឃៈកម្ម ឬ ចាត់ទុកថា គ្មាន។ មោឃៈភាព ត្រូវបានធ្វើការបែងចែកជាពីគឺ មោឃៈភាពដាច់ខាត និងមិនដាច់ខាត ប៉ុន្តែមោឃៈភាពត្រូវប្រកាសឡើងឈរលើច្បាប់ដែរបានចូលជាធរមាន ឬ នីតិវិធីវិជ្ជមាន។ ក្នុងករណីដែលមានច្បាប់ថ្មីចូលជាធរមាន ត្រូវយកមកអនុវត្តភ្លាម និងមិនប្រតិសកម្ម។ គោលបំណងដែលបង្កើតអោយមានមោឃៈភាពសំដៅលើការ ការធានាចំពោះនីតិវិធីឲ្យមានភាពត្រឹមត្រូវ ស្របទៅតាមច្បាប់ដែលចែងចូលជាធរមាន និងកំហិតទៅលើសកម្មភាពមន្ត្រីអនុវត្តច្បាប់ បូកផ្សំទាំងការការពារធានាសិទ្ធិការពារខ្លួនជនល្មើស ឬ ជនត្រូវចោទ។

មោឃៈភាពអាចកើតឡើងជា២ស្ថានភាព៖ ស្ថានភាពទី១ មោឃៈភាពដាច់ខាត មានចរិកលក្ខណៈដោយស្វ័យប្រវត្តិ ពោលគឺមិនទាមទារអោយមានប្តឹងទេ។ រីឯស្ថានភាពទី២ មោឃៈភាពមិនដាច់ខាត មានចរិកលក្ខណៈដោយមានការទាមទារអោយមានបណ្តឹងសុំមោឃៈភាព ពោលគឺមិនស្វ័យប្រវត្តិនោះទេ។ នីតិវិធីមោឃៈភាព គឺជាសមត្ថកិច្ចផ្តាច់មុខរបស់ សភាស៊ើបសួរ។ មានតែសមត្ថកិច្ចសភាស៊ើបសួរតែមួយគត់ដែលអាចមានចំណាត់ការទៅលើនីតិវិធីមួយនេះ។ សមត្ថកិច្ចកិច្ចនេះបូកបញ្ចូលរួមទាំង ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអាយ្យការ ដំណាក់ស៊ើបសួរ។ យ៉ាងណាមិញ មិនថាដំណាក់កាលមួយណាទេ ឲ្យតែមានការបំពានច្បាប់ ទម្រង់ច្បាប់ និងលក្ខខណ្ឌច្បាប់ សុទ្ធសឹងតែអាចលើកយកមោឃៈភាពមកតវ៉ា ឬ ជំទាស់បាន។ ប៉ុន្តែការតវ៉ា ឬ ជំទាស់នេះមិនអាចលើកឡើងចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។ សភាស៊ើបសួរគឺជាសភាពិសេសនៃសាលាឧទ្ធរណ៍ ឬ យើងអាចនិយាយបានម្យ៉ាងទៀតថាជាស្ថាប័នជាន់ខ្ពស់នៃសាលាឧទ្ធរណ៍។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ កិច្ចស៊ើបសួរដែលមានលក្ខណៈជាសេចក្តីសម្រេចនេះតែងស្តែងឡើងក្រោមរូបភាព **ដីកា** ហើយដីកានេះឲ្យឈ្មោះថា **ដីកាសម្រេច**។ ហើយជាគោលការណ៍ ដើម្បីអនុវត្តនូវសិទ្ធិ អំណាចមួយនេះ សភាស៊ើបសួរត្រូវបានគេប្តឹង គឺគាត់មិនមានសិទ្ធិពិនិត្យដោយខ្លួនឯងនោះទេ គឺលុះត្រាតែមាននរណាម្នាក់ប្តឹង។

នៅក្នុងយុត្តាធិការការស៊ើបសួរ យើងពិនិត្យឃើញមានពីមន្ទីរស៊ើបសួរនៅតាមសាលាដំបូងរាជធានី-ខេត្តទាំងអស់ដែលមន្ទីរស៊ើបសួរនេះ នៅពេលធ្វើការបំពេញកិច្ចរបស់ខ្លួនគឺ មានចៅក្រមស៊ើបសួរមួយរូបដែលជាចៅក្រមស៊ើបសួរ។ រីឯចំពោះសភាស៊ើបសួរវិញគឺស្ថិតនៅក្នុងសាលាឧទ្ធរណ៍ នៅពេលដែលបំពេញកិច្ចរបស់ខ្លួនជាពិសេសនៅពេលជំនុំជម្រះសម្រេចជាសាលដីកាទៅលើប្តឹងតវ៉ានឹងនីតិវិធី និងការសម្រេចរបស់ចៅក្រមស៊ើបសួរគឺត្រូវធ្វើដោយមានចៅក្រមបីរូប។ នៅក្នុងសភាស៊ើបសួរមានរចនាសម្ព័ន្ធរបស់ខ្លួនគឺថា ប្រធានមួយរូប និង

សមាជិកមួយចំនួនដែលសុទ្ធសឹងតែជាចៅក្រមហើយមានជំនួយការគឺជាក្រឡាបញ្ជី។ សភាស៊ើបសួរបង្កើតឡើងក្នុងគោលបំណង ដើម្បីពិនិត្យនិយ័តភាពនៃនីតិវិធីរបស់ចៅក្រមស៊ើបសួរ ឬ មន្ទីរស៊ើបសួរនៃសាលាដំបូងរាជធានី-ខេត្ត ទាំងអស់ដើម្បីធ្វើយ៉ាងណាឲ្យការស៊ើបសួរនេះល្អ ត្រឹមត្រូវទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ សភាស៊ើបសួរមានសមត្ថកិច្ចយ៉ាងច្រើនដូចជាៈ ពិនិត្យនិយ័តភាពនូវការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ប៉ុន្តែក៏យើងមើលឃើញថាសភាស៊ើបសួរនេះមានចំណុចពិសេសមួយគឺ មានអំណាចឲ្យប្រធានសភាស៊ើបសួរដែលជាអំណាចពិសេសមួយចំនួន។ ការពិនិត្យទៅលើនិយ័តភាពនៃនីតិវិធីមានន័យថា សភាស៊ើបសួរត្រូវពិនិត្យមើលថា តើការប្រព្រឹត្តទៅការបំពេញកិច្ចស៊ើបសួរ ឬ កិច្ចនីតិវិធីផ្សេងៗនោះត្រូវបានបំពេញតាមលក្ខខណ្ឌច្បាប់ដែរ ឬទេ ? និយាយម្យ៉ាងទៀតបានថាកិច្ចនោះ ធ្វើត្រឹមត្រូវតាមច្បាប់ដែរ ឬទេត្រឹមត្រូវតាមក្រមនីតិវិធីព្រហ្មទណ្ឌដែរឬទេ ប្រសិនបើមានកិច្ចណាមួយ ដែលមិនត្រឹមត្រូវសភាស៊ើបសួរអាចពិនិត្យលើលទ្ធភាពហើយក្នុងករណីដែលគាត់រកឃើញថាមានកំហុសគាត់អាចសម្រេចធ្វើមោឃៈកម្មបាន។

យើងខ្ញុំជឿជាក់ថា ក្រោមការអនុវត្តន៍នីតិវិធីមោឃៈភាពនេះ និងសម្រួលដល់ការអនុវត្តសិទ្ធិស្របច្បាប់នៃនីតិវិធី សិទ្ធិការពារខ្លួន និងធានាដល់ការអនុវត្តច្បាប់ដោយភាពត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាព។ ជាចុងក្រោយខ្ញុំបានសង្ឃឹមថា ការស្រាវជ្រាវអត្ថបទនេះជាចំណេះដឹង ហើយជាប្រយោជន៍មួយជូនដល់សាធារណៈ សង្គម និងមិត្តនិស្សិត សម្រាប់ការសិក្សា ក៏ដូចជាជំនាញការងារផងដែរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវ និងតាមរយៈការសាកសួរមន្ត្រីដែលបានអនុវត្តច្បាប់ ស្តាប់រួចមកហើយ យើងបានសង្កេតឃើញថា គប្បីមានការកែប្រែនូវចំណុចមួយចំនួននៅក្នុងគោលបំណងដើម្បី ឲ្យមានការអនុវត្ត កាន់តែមានប្រសិទ្ធភាព ទៅតាមការកំណត់ក្នុងច្រើស្តីនឹងទទួលបានទំនុកចិត្តពីសាធារណៈជនក៏ដូចជាជនត្រូវ ចោទ យើងខ្ញុំសូមលើកយកអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ធានាអោយមានការអនុវត្តស្របទៅតាមច្បាប់កំណត់ ពោលគឺអនុវត្តមិនគិតទៅតាមចិត្តចង់។
- ពន្លឿននីតិវិធីអោយមានឆាប់រហ័ស។
- ត្រូវមានការគោរពចំពោះសិទ្ធិរបស់ជនល្មើស ជនសង្ស័យ ឬ ជនជាប់ចោទ។

ធានាឲ្យមានគោលការណ៍សេរីភាពរបស់ជនជាប់ចោទខ្ពស់គឺជៀសវាងក្នុងករណីមួយចំនួនដែលឃុំខ្លួន បណ្តោះអាសន្នមិនមែនជាការចាំបាច់ ។

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តជាតិ

- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

## លិខិតបទដ្ឋានអន្តរជាតិ

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨

## សៀវភៅ

- នីតិវិធីព្រហ្មទណ្ឌ លោកគ្រូកើត រិទ្ធ
- សេចក្តីសង្ខេបក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣ រៀបរៀងដោយៈ សុង ប៊ុនឃៀង និង អាគ ច័ន្ទតារា
- មេរៀនស្តីពី គោលការណ៍ទូទៅនៃក្រមនីតិវិធីព្រហ្មទណ្ឌ លោកព្រះរាជអាជ្ញា ប្លង់ សុផល
- នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយៈ លោក រុន ពណ្ណរិទ្ធិ និង លោកស្រី ចាំង ស៊ីណាត

## គេហទំព័រ

- បទប្បញ្ញត្តិដែលមានចែងពីមោឃភាពនីតិវិធី ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ https://www.facebook.com/photo.php?fbid=1049105221942620&set=pcb.1049106638609145&type=3&theater
- សភាស៊ើបសួររៀបរៀងដោយ ស៊ាង សភស់ https://drive.google.com/file/d/0B2VpPgHdMaWzNHpaaG8tZGVzekk/view?fbclid=IwAR3YyA-vH8T13nkN9jOUy77ZAGGIA7fI2t_1T4vmMja_ptWfVZdiR28W3GQ
- នីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា ដោយ ចក សម្បត្តិ ជាព្រះរាជអជ្ញារង និង អនុប្រធានសមាគមសាលាត្រជូ d/1PAoWZMLIF78_Lu9uYs7N3DlsvrkhFUlK/view?fbclid=IwAR3dm0US5ftkuih8ueIhQ2qHkq3qKPJVZI0FA1p-NV77HsgC_1QOfunN7AI

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

3

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន |
| ០២ | ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ |
| ០៣ | កំណត់ហេតុសួរចម្លើយជនត្រូវចោទ |
| ០៤ | ដីកាឃុំខ្លួនបណ្ដោះអាសន្ន |
| ០៥ | ដីកាអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន |
| ០៦ | ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ |
| ០៧ | របាយការណ៍ព្រហ្មទណ្ឌ |
| ០៨ | សាលដីកា សភាស៊ើបសួរ |